# ព្រះអភិធម្មត្ថសង្គហៈ

## បរិច្ឆេទ ទី៧

## ភាគ ១

# សមុច្ចយសង្គហវិភាគ

រៀបរៀងដោយ
ខ្ញុំព្រះករុណា
ខ្ញុំបាទ រស់ សុផាត

សាលារៀនសតិប្បដ្ឋានខេត្តបាត់ដំបង
ឆ្នាំសិក្សា ព.ស ២៥៥0

# អារម្ភកថា

យើងខ្ញុំទាំងអស់គ្នាជាសិស្សគណ អ្នកសិក្សារៀនសូត្រនូវព្រះអភិធម្មនៅសាលារៀនសតិប្បដ្ឋានខេត្តបាត់ដំបង ដែលបង្ហាត់បង្រៀនដោយលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស** និង លោកគ្រូ-ធម្មាចារ្យ **រស់ សុផាត** បានសុំការអនុញ្ញាតអំពីលោកគ្រូដើម្បីយកមេរៀនដែលលោកគ្រូបង្រៀន មករៀបចំជាសៀវភៅ វាយដោយអក្សរកុំព្យូទ័រ សម្រាប់ជាធម្មទាន ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ និង ដើម្បីសេចក្ដីសុខដល់ខ្លួនឯងផង ដល់ពពួកជនទាំងឡាយផង និងដើម្បីការតាំងនៅនៃព្រះសទ្ធម្មផង ។

សូមសាធុជនទាំងឡាយ តាំងចិត្តសិក្សានូវខ្លឹមសារនៃព្រះអភិធម្មនោះឯង ដោយសេចក្ដីគោរពចុះ ។

- ដឹកនាំយកមកវាយកុំព្យូទ័រដោយភិក្ខុអគ្គបណ្ឌិតោ **យន់ សុផាត**
- រចនាអក្សរកុំព្យូទ័រដោយ ឧបាសក **អ៊ឹម វ៉ៃយ៉ា**
- ពិនិត្យអក្ខរាវិរុទ្ធដោយ ឧបាសក **ជិម ជំនិត**

សាលារៀនសតិប្បដ្ឋាន

ខេត្តបាត់ដំបង

# ព្រះអភិធម្មត្ថសង្គហៈ

## សមុច្ចយសង្គហវិភាគ បរិច្ឆេទទី៧

មាតិកា ................................................. លេខទំព័រ


១-បទផ្តើម ............................................. ១

២-អកុសលសង្គហៈ ................................... ៦

៣-អាសវៈ .............................................. ៨

៤-ឱឃៈ ................................................. ១៧

៥-យោគៈ ............................................... ២១

៦-គន្ថៈ .................................................. ២៤

៧-ឧបាទាន ............................................. ២៩

៨-នីវរណៈ .............................................. ៣៤

៩-អនុស័យ ............................................. ៤៣

១០-សំយោជនៈ ........................................ ៤៩

១១-កិលេស ............................................. ៦៣

១២-មិស្សកសង្គហៈ .................................... ៧២

១៣-ហេតុ ................................................ ៧៤

១៤-ឈានង្គៈ ........................................... ៧៧

១៥-មគ្គង្គៈ ............................................. ១០៨

១៦-ឥន្ទ្រិយ ............................................. ៨៩

១៧-ពលៈ ................................................ ១០៥

១៨-អធិបតី .............................................. ១១២

# ព្រះអភិធម្មត្ថសង្គហៈ

## បរិច្ឆេទ ទី៧

## សមុច្ចយសង្គហវិភាគ

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស*

### បទផ្ដើម

*ពាក្យថា **សមុច្ចយសង្គហ** នេះ កាលបើបានកាត់នូវបទហើយ មានដូចតទៅនេះ គឺ :*

***សំ + ឧច្ចយ = សមុច្ចយ***

***សំ** ប្រែថា ចូលជាមួយគ្នា ឬធម៌ដែលមានសភាពចូលជាមួយគ្នាបាន ។*

***ឧច្ចយ** ប្រែថា រួបរួម ។*

*កាលបើបញ្ចូលរួមទាំងពីរបទបានជា **សមុច្ចយ** ប្រែថា ការរួបរួមចូលជាមួយគ្នា ឬ ការរួបរួមនូវធម៌ដែលមានសភាពចូលគ្នាបាន ដូចមានវចនត្ថថា :*

សហ ឧច្ចីយន្តេ ឯត្ថាតិ = សមុច្ចយោ វា

សំ បិណ្ឌេត្វា ឧច្ចីយន្តេ ឯតេនាតិ = សមុច្ចយោ

ប្រែថា បរិច្ឆេទដែលឈ្មោះថា **សមុច្ចយ** ព្រោះជាបរិច្ឆេទដែលសម្ដែងនូវការប្រមូលបរមត្ថធម៌ទាំង៤ ប្រការព្រមគ្នា ឬថា បរិច្ឆេទដែលឈ្មោះថា **សមុច្ចយ** ព្រោះជាហេតុឲ្យសម្ដែងនូវការប្រមូលបរមត្ថធម៌ ដែលមានសភាពចូលជាមួយគ្នាបានឲ្យនៅជាពួកៗ ។

ក្នុងបរិច្ឆេទទី៧នេះ ព្រះអនុរុទ្ធាចារ្យបានរចនាប្រព័ន្ធ-គាថាសង្គហៈ ទុកជាគោលក្នុងការសម្ដែងសមុច្ចយសង្គហៈនេះជា ១៤ គាថា ជាមួយគ្នា ដូចជាការសម្ដែងអនុសន្ធិនិងប្ដេជ្ញាទុកក្នុងគាថាសង្គហៈទី១ ថា :

## គាថាសង្គហៈ ទី១

ទ្វាសត្តតិវិធា វុត្តា វត្ថុធម្មា សលក្ខណា
តេសំ ទានិ យថាយោគំ បវក្ខាមិ សមុច្ចយំ

ប្រែថា វត្ថុធម៌ គឺធម៌ដែលមានសភាវលក្ខណៈរបស់ខ្លួន

ដោយពិតប្រាកដ ៧២ ប្រការ នោះបានសម្ដែងរួចហើយ ឥឡូវនេះនឹងសម្ដែងនូវសមុច្ចយសង្គហៈ គឺ សម្ដែងនូវការរួបរួមធម៌ផ្សេងៗ របស់វត្ថុធម៌ ៧២ ប្រការនោះ តាមដែលនឹងអាចចូលជាមួយគ្នាបាន ។

## អធិប្បាយ

ពាក្យថា **វត្ថុធម៌** មានន័យថា ធម៌ដែលមានសភាវលក្ខណៈ គឺ អង្គធម៌បរមត្ថរបស់ខ្លួនដោយចំពោះ ដែលអាចប្រាកដដល់បញ្ញាបាន ។

ដូច្នេះបណ្ដាវត្ថុដែលមានជីវិត និងមិនមានជីវិតទាំងឡាយ ប្រសិនបើ រាប់យកតែធម៌ដែលមានសភាវលក្ខណៈរបស់ខ្លួនដោយចំពោះហើយ ក៏រមែងមានត្រឹមតែ៧២ប្រការប៉ុណ្ណោះគឺ :

**ចិត្ត** ៨៩ ឬ ១២១ ដួង ទាំងអស់ បំព្រួញយកតែ ១ គិតដោយសភាវលក្ខណៈ គឺ មានការដឹងអារម្មណ៍ជាលក្ខណៈ **អារម្មណវិជាននលក្ខណំ** ។

**ចេតសិក** ៥២ គិតដោយសភាវលក្ខណៈរបស់ខ្លួនហើយ សភាវលក្ខណៈរបស់ខ្លួននោះមាន ៥២ ។

**រូបទាំងអស់** គិតយកតែនិប្ផន្នរូបប៉ុណ្ណោះ ហើយនិប្ផន្ន-រូបនោះ ក៏មានច្រើនប្រភេទដូចគ្នា គឺ កម្មជនិប្ផន្នរូបក៏មាន ចិត្តជនិប្ផន្នរូបក៏មាន ឧតុជនិប្ផន្នរូបក៏មាន អាហារជនិប្ផន្នរូប ក៏មាន ប៉ុន្តែកាលណាពោលដោយសភាវលក្ខណៈហើយ ក៏មានត្រឹមតែ ១៨ ប៉ុណ្ណោះ ទើបរាប់យកនិប្ផន្នរូប ១៨ ។

ដូច្នោះរូបទាំងអស់ គិតតាមសភាវលក្ខណៈដែលមាននៅក្នុងរូបធម៌ដោយចំពោះ រមែងបានដល់និប្ផន្នរូប ១៨ ។

**និព្វាន** ១ គិតតាមសភាវលក្ខណៈគឺ សន្តិលក្ខណំ ។

ចំណែកអនិប្ផន្នរូប ១០ នោះ មិនមានសភាវលក្ខណៈរបស់ខ្លួនដោយចំពោះទេ រូបទាំង១០នោះគ្រាន់តែជាការកំណត់រូបកលាបដល់រូបកលាប និងអាការប្រព្រឹត្តទៅរបស់និប្ផន្នរូបប៉ុណ្ណោះ ទើបមិនចាត់ចូលនៅក្នុងវត្ថុធម៌ឲ្យជាពិសេសឡើងទៅទៀត ទើបគង់មានវត្ថុធម៌ត្រឹមតែ ៧២ ប៉ុណ្ណោះ ។

ម្យ៉ាងទៀត ការសម្ដែងនូវវត្ថុធម៌ទាំង ៧២ ប្រការនោះ ព្រះអនុរុទ្ធាចារ្យ បានសម្ដែងរួចមកហើយដោយពិស្ដារ តាំងពីបរិច្ឆេទទី១ជាដើមរហូតដល់បរិច្ឆេទទី៦ ។ ដូច្នោះក្នុងបរិច្ឆេទ

ទី៧ នេះ លោកប្រាថ្នានឹងសម្តែងនូវការបង្រួបបង្រួមនូវចិត្ត ចេតសិក រូប និព្វាន ដែលហៅថា វត្ថុធម៌ ៧២ ប្រការនោះ តាមដែលនឹងអាចបង្រួបបង្រួមចូលគ្នាជាពួកជាក្រុម បានវារៈមួយទៀត ទើបមានឈ្មោះថា "**សមុច្ចយសង្គហៈ**" ដែលរួបរួមនូវសភាវធម៌ដែលចូលគ្នាបានជា៤ ពួក ដូចមានវចនត្ថថា :

*អកុសលសង្គហោ មិស្សកសង្គហោ*
*ពោធិបក្ខិយសង្គហោ សព្វសង្គហោ*
*ចេតិសមុច្ចយសង្គហោ ចតុព្វិធោ*
*វេទិតព្វោ ។*

ប្រែថា សមុច្ចយសង្គហវិភាគនេះ ចែកចេញជា៤ពួក គឺ

**១-អកុសលសង្គហៈ** សម្តែងការរួបរួមនូវអកុសលធម៌ផ្សេង ៗ ដោយការចែកទៅតាមអាការរបស់កិលេស ។

**២-មិស្សកសង្គហៈ** សម្តែងនូវការសង្គ្រោះសភាវធម៌ផ្សេង ៗ ដែលជាកុសល អកុសល អព្យាកតៈទាំង ៣ ប្រឡូកចូលគ្នា ។

**៣ - ពោធិបក្ខិយសង្គហៈ** សម្តែងការរួបរួមធម៌ដែល

ជាផ្នែកនៃមគ្គញ្ញាណ ។

**៤ - សព្វសង្គហៈ** សម្តែងការរួបរួមបរមត្ថធម៌ទាំងអស់ គឺ ចិត្ត ចេតសិក រូប និង និព្វានដែលជាវត្ថុធម៌ ។

តទៅនេះ នឹងបើកសម្តែងនូវសមុច្ចយសង្គហៈទាំង៤ពួកទៅតាមលំដាប់ដូចតទៅ :-

## ពួក ទី ១

## អកុសលសង្គហៈ

អកុសលសង្គហៈ សម្តែងនូវការរួបរួមអកុសលធម៌ផ្សេងៗ ដោយចែកទៅតាមអាការនៃកិលេសដែលមានវចនត្ថថា :-

**ឯកន្តាកុសលជាតិកានំ ឱឃចតុក្កាទីនំ**

**សង្គហោតិ = អកុសលសង្គហោ**

ប្រែថា ពួកធម៌ដែលសង្គ្រោះសភាវធម៌ផ្សេង ៗ មានឱឃៈ ៤ ជាដើម ដែលជាអកុសលជាតិទាំងអស់ ដូច្នេះទើបឈ្មោះថា **អកុសលសង្គហៈ** ដែលមានគាថាសង្គហៈសម្តែងថា:

## គាថាសង្គហៈ ទី២

**អាសវោឃា ច យោគា ច តយោ គន្ថា ច វត្ថុតោ**
**ឧបាទានា ទុវេ ធម្មា អដ្ឋ នីវរណា សិយុំ**

ប្រែថា អាសវៈ ឱឃៈ យោគៈ និង គន្ថៈទាំងអស់នេះ កាលបើពោលដោយអង្គធម៌បរមត្ថហើយ នីមួយៗមានអង្គធម៌បរមត្ថ៣ ឧបាទានមានអង្គធម៌បរមត្ថ២ និងនីវរណៈមានអង្គធម៌បរមត្ថ ៨ ។

## គាថាសង្គហៈ ទី៣

**ឆឡេវានុសយា ហោន្តិ នវ សំយោជនា មតា**
**កិលេសា ទស វុត្តោយំ នវធា បាបសង្គហោ**

ប្រែថា អនុស័យមានអង្គធម៌បរមត្ថ៦ សំយោជនៈមានអង្គធម៌បរមត្ថ៩ កិលេសមានអង្គធម៌បរមត្ថ១០ ។

រួមសេចក្តីមកអកុសលសង្គហៈមានធម៌ ៩ កង គឺ :

១-អាសវៈ ២-ឱឃៈ ៣-យោគៈ ៤-គន្ថៈ ៥-ឧបាទាន ៦-នីវរណៈ ៧-អនុស័យ ៨-សំយោជនៈ ៩-កិលេស ដែល

នឹងបានសម្តែងអកុសលសង្គហៈ ៩កង ដោយលំដាប់តទៅ :

## ១ - អាសវៈ

**អាសវៈ** សំដៅយកគ្រឿងត្រាំនៅដ៏យូរ ឧបមាដូចជា សុរាជាវត្ថុដែលត្រូវត្រាំទុកយូរណាស់ ទើបបណ្តាលឲ្យអ្នកពិសាអាចស្រវឹងបាត់ស្មារតី អាចធ្វើនូវអំពើដែលមិនគួរធ្វើបាន យ៉ាងណា សភាពនៃធម៌ដែលជាគ្រឿងត្រាំដ៏អង្វែងនៅក្នុងខន្ធសន្តានរបស់សត្វ ក៏ធ្វើឲ្យសត្វទាំងឡាយត្រូវស្រវឹងវង្វេងវង្វាន់ភ្លេចស្មារតី អាចប្រព្រឹត្តនូវអំពើដែលមិនគួរធ្វើបាន ក៏យ៉ាងនោះដែរ សភាវធម៌នេះឯងឈ្មោះថា **អាសវៈ** ។ អាសវៈដែលជាសភាវធម៌នេះ បានដល់ **លោភៈ ទិដ្ឋិ មោហៈ** ធម៌ទាំង ៣ ប្រការនេះ ត្រាំត្រែងនៅក្នុងខន្ធសន្តានរបស់សត្វទាំងឡាយដោយកាលជាអង្វែង ដែលមិនអាចរាប់កពរាប់ជាតិបានឡើយ។ ធម៌ទាំងនេះកាលប្រាកដនៅក្នុងបុគ្គលណា ធ្វើឲ្យចិត្តសន្តានរបស់បុគ្គលនោះ ស្រវឹងវង្វេង ភ្លេចស្មារតី ក៏ធ្លាក់ក្នុងអំណាចនៃ លោភៈខ្លះ ទិដ្ឋិខ្លះ និង មោហៈខ្លះ ជាហេតុឲ្យ

ហ៊ានធ្វើនូវអំពើទុច្ចរិតផ្សេងៗ មានកាយទុច្ចរិតជាដើម ។

ព្រោះសេចក្តីស្រវឹងដោយលោភៈ ទិដ្ឋិ មោហៈ នោះឯង ទើបព្រះមានព្រះភាគទ្រង់សម្តែងវចនត្ថថា :

**អាសវន្តិ ចិរំ បរិវសន្តីតិ = អាសវា**

គ្រឿងវត្ថុណា ត្រូវត្រាំនៅយូរ គ្រឿងវត្ថុនោះឈ្មោះថា អាសវៈ ( បានដល់សុរា ) ។

**អាសវា វិយាតិ = អាសវា**

ធម្មជាតិណា មានសភាពដូចសុរា ធម្មជាតិនោះ ឈ្មោះថា អាសវៈ ( បានដល់ លោភៈ ទិដ្ឋិ មោហៈ ) ។ ពាក្យថា **អាសវ** ចែកចេញបានជា២បទ គឺ **អា** + **សវ** = **អាសវ** ។

**អា** ប្រែថា វដ្តទុក្ខដ៏អន្លង់ដែលមិនមានកំណត់ ។

**សវ** ប្រែថា ចម្រើនរុងរឿង ។

កាលបង្រួមចូលទាំង ២ បទ ហើយ ប្រែថាធម៌ដែលធ្វើឲ្យវដ្តទុក្ខដ៏យូរអន្លង់មិនមានកំណត់នោះ ចម្រើនរុងរឿងមិនមានទីបំផុត ។

បានសេចក្តីថា ការប្រព្រឹត្តិទៅនៃរូបនាមខន្ធ៥របស់សត្វ

ទាំងឡាយ ម្នាក់ៗសុទ្ធតែកើតហើយស្លាប់ ស្លាប់ហើយកើត រស់នៅដូចយ៉ាងនេះទៀត មិនមានកំណត់អស់ជាអង្វែងហើយ និងតទៅខាងមុខ ក៏រមែងនឹងត្រូវស្លាប់ហើយកើត កើតហើយស្លាប់តែយ៉ាងហ្នឹងតទៅទៀតៗ សេចក្តីនេះបង្ហាញឲ្យឃើញថា វដ្តទុក្ខរបស់សត្វទាំងឡាយនោះ ចម្រើនរុងរឿងជាអនេកមិនមានទីបំផុត ដូចមានវចនត្ថសម្តែងថា :

**អាយតំ សំសារទុក្ខំ សវន្តិ**

**បសវន្តិ វាឌ្ឍេន្តីតិ = អាសវា**

ប្រែថា ធម៌ទាំងឡាយណាធ្វើឲ្យវដ្តៈដ៏យូរអង្វែងនោះ ចម្រើនរុងរឿង ធម៌ទាំងឡាយនោះឈ្មោះថា អាសវៈ ( បាន ដល់ លោភៈ ទិដ្ឋិ មោហៈ ) ។

ន័យម្យ៉ាងទៀត ពាក្យថា **អា** ប្រែថា មានដែនកំណត់ដល់ភវគ្គភូមិ គឺ នេវសញ្ញានាសញ្ញាយតនភូមិ ឬមានដែនកំណត់ដល់គោត្រភូ ។

ពាក្យថា **សវ** ប្រែថា កើតបាន ឬហូរទៅបាន ។

កាលរួមទាំង២បទចូលគ្នា ប្រែថា កើតបាន ឬហូរទៅបាន រហូតដល់ភវគ្គភូមិ ឬគោត្រភូ ដោយអំណាចការធ្វើឲ្យជាអារម្មណ៍ ។

តាមធម្មតា លោភ: ទិដ្ឋិ មោហ: ទាំង៣នេះកើតឡើង ដោយអាស្រ័យលោកិយធម៌ និង បញ្ញត្តិធម៌ស្រេចទៅហើយ ដូច្នេះដែលសម្ដែងថា កើតបានរហូតដល់ភវគ្គភូមិ ឬគោត្រភូនោះ មិនមានសេចក្ដីពិសេសយ៉ាងណាទេ បានសេចក្ដីថា នេវសញ្ញានាសញ្ញាយតនភូមិក៏ដោយ គោត្រភូក៏ដោយ ឬ វោទានក៏ដោយ ទាំងនេះនៅជាលោកិយធម៌ ដូច្នេះហើយទើបជាអារម្មណ៍របស់លោភ: ទិដ្ឋិ មោហ: អាសវធម៌ទាំង៣នេះ កើតបាន ឬហូរទៅបានរហូតដល់ភវគ្គភូមិ ឬគោត្រភូ ដូចមានវចនត្ថថា :

**ភវតោ អាភវគ្គា ធម្មតោ អាគោត្រភុម្ហា សវន្តិ អារម្មណករណវសេន បវត្តន្តីតិ = អាសវា**

ប្រែថា ធម៌ទាំងឡាយណាហូរទៅដល់ ឬកើតបាន កាលពោលដោយភូមិ ដល់ភវគ្គភូមិ កាលពោលដោយធម៌ ដល់គោត្រភូ ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ដូច្នេះធម៌ទាំងនោះឈ្មោះថា **អាសវ:** ។

មានចំណុចដែលគួរសង្ស័យដែរថា លោភៈ ទិដ្ឋិ មោហៈ ទាំង៣នេះ ឈ្មោះថា **អាសវៈ** ព្រោះជាគ្រឿងត្រាំនៅក្នុងខន្ធ-សន្តានរបស់សត្វទាំងឡាយ ដោយកាលជាអង្វែង ឬហូរទៅបាន កើតបានរហូតដល់ភវគ្គភូមិ ឬគោត្រភូ តាមដែលបានសម្តែងមកហើយនោះ កាលបើជាយ៉ាងនេះ ចុះអកុសល-ចេតសិកដទៃៗ ដូចជាអហិរិកៈ អនោត្តប្បៈ មានៈ ជាដើម ក៏កើតនៅក្នុងខន្ធសន្តានរបស់សត្វទាំងឡាយមក អស់កាលជាយូរអង្វែងដែរ ហើយក៏អាចកើតបានដោយអាស្រ័យភវគ្គភូមិ ឬគោត្រភូជាអារម្មណ៍ដូចតែគ្នាទេតើ ហេតុអ្វី ព្រះសម្មាសម្ពុទ្ធព្រះអង្គទើបមិនទ្រង់ចាត់អកុសលចេតសិកទាំងនោះជាអាសវៈដែរទៅ ព្រោះហេតុអ្វី ?

ឆ្លើយថា ទាំងនេះព្រោះ លោភៈ ទិដ្ឋិ មោហៈ ទាំង ៣ នេះ មានសភាពធំទូលាយ និង ប្រាកដជាក់ច្បាស់ច្រើនជាងអកុសលចេតសិកដទៃ ៗ ទៀត ប្រៀបបីដូចជាពន្លឺព្រះអាទិត្យរមែងបញ្ចាំងពន្លឺភ្លឺច្បាស់ជាងពន្លឺដទៃៗ ដូចជាពន្លឺព្រះចន្ទ ឬពន្លឺភ្លើងជាដើម ។

អកុសលចេតសិកដួងដទៃ ៗ សូម្បីតែអាចជាគ្រឿងត្រាំនៅក្នុងខន្ធសន្តានរបស់សត្វទាំងឡាយ ឬអាចហូរទៅបាន កើតបានរហូតដល់ភវគ្គភូមិ និង គោត្រភូ ដោយអំណាចធ្វើឲ្យជាអារម្មណ៍ក៏ពិតមែន ប៉ុន្តែសភាពជាគ្រឿងត្រាំក្តីឬសភាពហូរទៅបាន កើតបានរហូតដល់ភវគ្គភូមិ និងគោត្រភូក្តី ទាំងអស់នេះរមែងជាក់ច្បាស់ក្រៃលែងជាង ប្រាកដតែក្នុងធម៌ដែលជា លោភៈ ទិដ្ឋិ មោហៈ មយ៉ាងប៉ុណ្ណោះ ហេតុដូច្នោះហើយ ទើបព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គមិនទ្រង់សម្តែងនូវអកុសល-ចេតសិកដួងដទៃ ៗ ទៀតថាជា **អាសវៈ** ឡើយ ។

ដូច្នេះធម៌ដែលជាគ្រឿងត្រាំ និង ហូរទៅបាន កើតបានរហូតដល់ភវគ្គភូមិ ឬគោត្រភូនោះ ចំពោះត្រង់តែប្រាកដច្បាស់ជាង គឺបានដល់លោភៈ ទិដ្ឋិ មោហៈ តែមួយចំណែកប៉ុណ្ណោះដែលជា **អាសវៈ** ។

**អាសវៈ** មាន៤ប្រការ គឺ :

**១ - កាមាសវៈ** ធម្មជាតិដែលជាគ្រឿងត្រាំ ឬហូរទៅបាននៅក្នុងកាមគុណអារម្មណ៍ អង្គធម៌បានដល់ លោភចេតសិក

ក្នុងលោភមូលចិត្ត ៨ ។

**២ - ភវាសវៈ** ធម្មជាតិដែលជាគ្រឿងត្រាំ ឬ ហូរទៅ អាស្រ័យដោយសេចក្តីត្រេកអរជាប់ចិត្តនៅក្នុងអត្តភាពនៃខ្លួន ក្នុងរូបភព អរូបភព ឬក្នុងរូបឈាន អរូបឈាន អង្គធម៌បានដល់ លោភចេតសិកក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ។

**៣ - ទិដ្ឋាសវៈ** ធម្មជាតិជាគ្រឿងត្រាំ ឬ ហូរទៅ អាស្រ័យដោយសេចក្តីយល់ខុស ឃើញខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិក ក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

**៤ - អវិជ្ជាសវៈ** ធម្មជាតិដែលជាគ្រឿងត្រាំ ឬហូរទៅ អាស្រ័យដោយសេចក្តីវង្វេង សេចក្តីល្ងង់ មិនដឹងហេតុផលតាមសេចក្តីពិត អង្គធម៌បានដល់ មោហចេតសិកក្នុងអកុសលចិត្ត១២ ។

ដូច្នេះអាសវៈទាំង ៤ ប្រការនេះ មានអង្គធម៌ត្រឹមតែ ៣ ប៉ុណ្ណោះ គឺ លោភចេតសិក១ ទិដ្ឋិចេតសិក១ និងមោហចេតសិក១ ។

ក្នុងអដ្ឋសាលិនីអដ្ឋកថា សម្តែងនូវសេចក្តីនៃអាសវៈទាំង ៤ ប្រការនេះថា :

**បញ្ច កាមគុណិកោ រាគោ កាមាសវោ នាម ។**

សេចក្តីត្រេកអរពេញចិត្តនៅក្នុងកាមគុណអារម្មណ៍ទាំង ៥ ឈ្មោះថា **កាមាសវៈ** ។

**រូបារូបភវេសុ ឆន្ទរាគោ ឈាននិកន្តិ សស្សតទិដ្ឋិ**
**សហជាតោ ភវវសេនា បត្ថនា ភវាសវោ នាម ។**

សេចក្តីត្រេកអរ ពេញចិត្តក្នុងរូបភព អរូបភព សេចក្តីពេញចិត្តនៅក្នុងឈានសមាបត្តិ សេចក្តីត្រេកអរពេញចិត្តក្នុងអារម្មណ៍ដែលកើតព្រមនឹងសស្សតទិដ្ឋិ សេចក្តីប្រាថ្នានូវភព ឈ្មោះថា **ភវាសវៈ** ។

**ទ្វាសដ្ឋីទិដ្ឋិយោ ទិដ្ឋាសវោ នាម ។**

សេចក្តីយល់ខុសក្នុងទិដ្ឋិ៦២យ៉ាងឈ្មោះថា ទិដ្ឋាសវៈ ។

**អដ្ឋសុ ឋានេសុ អញ្ញាណំ អវិជ្ជាសវោ នាម ។**

សភាពមិនដឹងក្នុងសភាវធម៌តាមសេចក្តីពិត ៨ ប្រការបានដល់ សេចក្តីមិនដឹងក្នុងអរិយសច្ចៈ៤ មិនដឹងក្នុង ខន្ធ អាយតនៈ ធាតុ ដែលជាអតីត១ ដែលនឹងប្រព្រឹត្តទៅក្នុងអនាគត១ មិនដឹងទាំងអតីត និងអនាគត១ និង មិនដឹងបដិច្ច-

សមុប្បាទ១ សភាពមិនដឹងនោះ ឈ្មោះថា **អវិជ្ជាសវៈ** ។

**ធម៌ដែលលះអាសវៈ ៤**

**កាមាសវោ អនាគាមិមគ្គេន បហីនយតិ**
**ភវាសវោ អរហត្តមគ្គេន ទិដ្ឋាសវោ**
**សោតាបត្តិមគ្គេន អវិជ្ជាសវោ អរហត្តមគ្គេន ។**

**កាមាសវៈ** លះបង់បានដោយបញ្ញាក្នុងអនាគាមិមគ្គចិត្ត។
**ភវាសវៈ** លះបង់បានដោយបញ្ញាក្នុងអរហត្តមគ្គចិត្ត ។
**ទិដ្ឋាសវៈ** លះបង់បានដោយបញ្ញាក្នុងសោតាបត្តិមគ្គចិត្ត។
**អវិជ្ជាសវៈ** លះបង់បានដោយបញ្ញាក្នុងអរហត្តមគ្គចិត្ត ។

## ២ - ឱឃៈ

ឱឃធម៌ សំដៅយកធម៌ដែលប្រៀបដូចជាអន្លង់ទឹក បានដល់ លោភៈ ទិដ្ឋិ មោហៈ ។ អកុសលចេតសិកទាំង ៣ ដូងនេះ ជាធម៌ដែលដូចជាអន្លង់ទឹកនោះ ព្រោះធម្មតាអន្លង់ទឹកកាលមានវត្ថុណាមួយ ឬសត្វណាមួយធ្លាក់ទៅក្នុងអន្លង់ទឹកហើយ ទឹកនោះតែងក្ងួចពន្លិចពន្លង់បៀតបៀនវត្ថុឬសត្វនោះ ៗ

ឲ្យលិចលង់មិនមានឱកាសនឹងងើប ឬផុសឡើងរួចបានដោយងាយឡើយ យ៉ាងណា សេចក្ដីលោភ សេចក្ដីយល់ឃើញខុស និងសេចក្ដីល្ងង់ខ្លៅគឺ លោភៈ ទិដ្ឋិ មោហៈ ធម៌ទាំង៣ប្រការនេះ ក៏ដូចគ្នាយ៉ាងនោះដែរ គឺ តែងពន្លិចពន្លង់បៀតបៀនសត្វទាំងឡាយ ឲ្យលិចលង់នៅក្នុងវដ្ដសំសារហូតដល់អបាយភូមិ ហើយកម្របានឱកាសដែលនឹងអាចងើប ផុសរួចពីសំសារវដ្ដចូលទៅកាន់ព្រះនិព្វានបានឡើយ ។

បានសេចក្ដីថា កាលសត្វទាំងឡាយត្រូវគ្របសង្កត់ដោយសេចក្ដីលោភ សេចក្ដីយល់ឃើញខុស និងសេចក្ដីល្ងង់វង្វេងហើយ រមែងត្រូវអំណាចនៃអកុសលទាំងនោះ ទាញនាំឲ្យធ្វើទុច្ចរិតកម្ម នាំទៅកាន់អបាយភូមិ ដែលជាភូមិទាប ហៅថា **ហេដ្ឋិមសំសារ**ដែលកម្រនឹងរកឱកាសបានរួចផុតចាកភូមិនោះណាស់ ឬពុំនោះទេ ក៏អាចទាញនាំឲ្យជាប់ជំពាក់ចិត្តក្នុងការអន្ទោលវិលវល់ ស្លាប់កើត នៅក្នុងភូមិដែលមានសេចក្ដីសុខសេចក្ដីសប្បាយដែលជាសុគតិភូមិកណ្ដាល ហៅថា **មជ្ឈិម-សំសារ** ឬ ភូមិខ្ពស់ ហៅថា **ឧបរិមសំសារ** ដែលក្នុងភូមិ

នីមួយៗ ដូចដែលបានពោលហើយនោះ ក៏សុទ្ធតែនៅមិនទាន់ផុតចាកវដ្តទុក្ខ ។

ដោយហេតុនោះ លោភៈ ទិដ្ឋិ មោហៈទាំង៣នេះ ទើបឈ្មោះថា **ឱឃៈ** គឺ អន្លង់ទឹក ដូចមានវចនត្ថសម្តែងថា :

**អវត្ថរិត្វា ហនន្តីតិ = ឱឃា វា**

ប្រែថា ធម្មជាតិណា តែងកួចពន្លិច បៀតបៀននូវសត្វទាំងឡាយ ធម្មជាតិនោះឈ្មោះថា **ឱឃៈ**(បានដល់អន្លង់ទឹក)។

និងន័យម្យ៉ាងទៀតសម្តែងថា :

**អវហនន្តីតិ ឱសីទាបេន្តីតិ = ឱឃា**

ប្រែថា ធម្មជាតិណារមែងធ្វើឲ្យសត្វទាំងឡាយលិចលង់ ធម្មជាតិនោះ ឈ្មោះថា **ឱឃៈ** ។

**ឱឃាវិយាតិ = ឱឃា**

ប្រែថា ធម្មជាតិទាំងឡាយណា កួចពន្លិចពន្លង់បៀត-បៀនសត្វទាំងឡាយ និងធ្វើឲ្យសត្វទាំងឡាយនោះលិចលង់នៅក្នុងសំសារវដ្ត រហូតដល់អបាយភូមិ ប្រហែលគ្នានឹងអន្លង់ទឹក ដូច្នេះធម៌ទាំងនោះ ឈ្មោះថា **ឱឃៈ** ( បានដល់ លោភៈ

ទិដ្ឋិ មោហៈ ) ។

ឱឃៈទាំងនេះក្តួចពន្ទិចទៅដល់ ឬកើតបាន កាលពោល ដោយភូមិ ដល់កវគ្គភូមិ កាលពោលដោយធម៌ ដល់គោត្រភូ ។

**ឱឃៈ** មាន៤ប្រការ គឺ :

**១ - កាមោឃៈ** ធម្មជាតិដែលធ្វើឲ្យសត្វលិចលង់នៅក្នុងអន្លង់នៃកាមគុណអារម្មណ៍ អង្គធម៌បានដល់លោភចេតសិកក្នុងលោភមូលចិត្ត ៨ ។

**២ - ភវោឃៈ** ធម្មជាតិដែលធ្វើឲ្យសត្វលិចលង់នៅក្នុងអន្លង់នៃសេចក្តីត្រេកអរ ក្នុងអត្តភាពរបស់ខ្លួន ក្នុងរូបភព-អរូបភព ឬក្នុងរូបឈាន-អរូបឈាន អង្គធម៌បានដល់លោភ-ចេតសិកក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ។

**៣ - ទិដ្ឋោឃៈ** ធម្មជាតិដែលធ្វើឲ្យសត្វលិចលង់នៅក្នុងអន្លង់នៃសេចក្តីយល់ឃើញខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

**៤ - អវិជ្ជោឃៈ** ធម្មជាតិដែលធ្វើឲ្យសត្វលិចលង់នៅ

ក្នុងអន្ទង់នៃសេចក្ដីវង្វេង សេចក្ដីល្ងង់ មិនដឹងសភាវធម៌តាមសេចក្ដីពិត អង្គធម៌បានដល់ មោហចេតសិក ក្នុងអកុសល-ចិត្ត ១២ ។ **ឱឃៈ** ទាំង៤ប្រការនេះ មានអង្គធម៌ត្រឹមតែ ៣ ប៉ុណ្ណោះ គឺ លោភចេតសិក ទិដ្ឋិចេតសិក និងមោហចេតសិក ។

## ធម៌ដែលលះបង់ឱឃៈ ៤

បញ្ញា ក្នុងសោតាបត្តិមគ្គចិត្តលះ ទិដ្ឋោឃៈ ។

បញ្ញា ក្នុងអនាគាមិមគ្គចិត្តលះ កាមោឃៈ ។

បញ្ញា ក្នុងអរហត្តមគ្គចិត្តលះ ភវោឃៈ និងអវិជ្ជោឃៈ។

## ៣ - យោគៈ

យោគធម៌ សំដៅដល់ធម៌ដែលជាគ្រឿងប្រកបសត្វលោកទុកឲ្យជាប់នៅក្នុងវដ្តទុក្ខ ដែលមានវចនត្ថថា :

**វដ្ដស្មឹ សត្តេ យោជេន្តីតិ = យោគា**

ធម៌ទាំងឡាយណា ជាគ្រឿងប្រកបសត្វទុកឲ្យជាប់នៅក្នុងវដ្តទុក្ខ គឺ ភពផ្សេងៗ ធម៌ទាំងឡាយនោះ ឈ្មោះថា **យោគៈ** ។

**យោគៈ** សំដៅយកគ្រឿងប្រកបដូចជា ការស្អិតតែង ប្រកបវត្ថុពីរផ្សេងគ្នា ឲ្យស្អិតជាប់គ្នាយ៉ាងណា លោភៈ ទិដ្ឋិ មោហៈ ក៏តែងប្រកបសត្វទាំងឡាយទុកឲ្យស្អិតជាប់នៅនឹងវដ្តទុក្ខបាន ក៏យ៉ាងនោះ ។

ន័យម្យ៉ាងទៀត ឧបមាដូចជា គោដែលត្រូវទឹមហើយក្នុងខ្សែទាមរទេះ កាលណាគោដើរទៅក្នុងផ្លូវណាៗ កាលនោះ ក៏តែងទាញ ឬអូសរទេះជាប់ទៅតាមជាមួយជានិច្ច យ៉ាងណា សត្វទាំងឡាយដែលត្រាច់រង្គាត់ ស្លាប់កើតនៅក្នុងវដ្តទុក្ខក៏ដូចគ្នា រមែងវិលវល់នៅក្នុងវដ្តទុក្ខ មិនរួចផុតចាកបាន ព្រោះត្រូវប្រកបទុកដោយ លោភៈ ទិដ្ឋិ មោហៈក៏យ៉ាងនោះដែរ ។

សេចក្តីអធិប្បាយក្នុងសេចក្តីឧបមានេះ ពាក្យថា **គោ** ជាឈ្មោះ របស់សត្វលោកទាំងឡាយ ។ ពាក្យថា **រទេះ** ជាឈ្មោះនៃកាមភព រូបភព អរូបភពដែលជាវដ្តទុក្ខ។ ពាក្យថា **ខ្សែទាម** ជាឈ្មោះនៃ លោភៈ ទិដ្ឋិ មោហៈ ដែលជាយោគ-ធម៌នោះឯង ។

ដូច្នេះសត្វលោកទាំងឡាយ ដែលវិលវល់ស្លាប់កើតនៅ

ក្នុងវដ្តទុក្ខ មិនរួចផុតទៅបាននោះ ក៏ព្រោះតែអំណាចរបស់ លោភៈ ទិដ្ឋិ មោហៈ ទាំង ៣ នេះឯង ជាអ្នកប្រកបសត្វទុក ឲ្យជាប់នៅ ទើបព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់សម្តែងថាលោភៈ ទិដ្ឋិ មោហៈ ទាំង ៣ នេះជា **យោគៈ** ។

ចំណែកអកុសលចេតសិកដទៃៗទៀត ដែលមិនបានឈ្មោះថា **យោគៈ** នោះ ក៏មានសេចក្តីទំនងដូចនឹងសេចក្តីក្នុងអាសវៈ ដែលបានពោលរួចហើយ ។

**យោគៈ** មាន ៤ ប្រការ គឺ :

**១ - កាមយោគៈ** ធម្មជាតិដែលជាគ្រឿងប្រកបសត្វឲ្យជាប់ស្អិតនៅក្នុងកាមគុណអារម្មណ៍ អង្គធម៌បានដល់ លោភ-ចេតសិកដែលប្រកបក្នុងលោភមូលចិត្ត ៨ ។

**២ - ភវយោគៈ** ធម្មជាតិដែលជាគ្រឿងប្រកបសត្វទុកឲ្យជាប់ស្អិតនៅក្នុងអត្តភាពនៃខ្លួន និងក្នុងរូបភព អរូបភព ឬ រូបឈាន អរូបឈាន អង្គធម៌បានដល់ លោភចេតសិកដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ។

**៣ - ទិដ្ឋិយោគៈ** ធម្មជាតិដែលជាគ្រឿងប្រកបសត្វឲ្យ

ជាប់ស្អិតនៅក្នុងសេចក្តីយល់ឃើញខុស អង្គធម៌បានដល់ ទិដ្ឋិ-
ចេតសិកដែលប្រកបក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

**៤-អវិជ្ជាយោគៈ** ធម្មជាតិដែលជាគ្រឿងប្រកបសត្វឲ្យ
ជាប់ស្អិតនៅក្នុងសេចក្តីវង្វេង សេចក្តីល្ងង់ មិនដឹងនូវធម៌
តាមសេចក្តីពិត អង្គធម៌បានដល់ មោហចេតសិកប្រកបក្នុង
អកុសលចិត្ត ១២ ។

យោគៈទាំង ៤ប្រការនេះ មានអង្គធម៌ត្រឹមតែ៣ប៉ុណ្ណោះ
គឺ លោភចេតសិក១ ទិដ្ឋិចេតសិក១ និងមោហចេតសិក១ ។

## ធម៌ដែលលះបង់យោគៈ ៤

បញ្ញាក្នុងសោតាបត្តិមគ្គចិត្តលះទិដ្ឋិយោគៈ ។
បញ្ញាក្នុងអនាគាមិមគ្គចិត្តលះកាមយោគៈ ។
បញ្ញាក្នុងអរហត្តមគ្គចិត្តលះភវយោគៈនិងអវិជ្ជាយោគៈ។

**សង្កេត** : អាសវៈ ឱឃៈ និង យោគៈ អកុសល-
សង្គហៈទាំង ៣ ប្រការ ដែលបានពោលហើយនេះ នីមួយ ៗ
មានធម៌៤ប្រការ និងមានអង្គធម៌ដូចគ្នា និងស្មើគ្នាគឺ លោភៈ

ទិដ្ឋិ មោហៈ ។

## ៤ - គន្ថៈ

**គន្ថៈ** ប្រែថា គ្រឿងចង សំដៅយកគ្រឿងចងសត្វឲ្យជាប់នៅក្នុងភព មានវចនត្ថថា :

**កាយំ គន្ថេតីតិ = កាយគន្ថា វា**

**កាយេន កាយំ គន្ថេតីតិ = កាយគន្ថា**

ប្រែថា ធម៌ទាំងឡាយណាចង គឺ កៀវថ្លក់ទុកនូវនាមកាយ ធម៌ទាំងនោះ ឈ្មោះថា **កាយគន្ថៈ** ។

ឬធម៌ទាំងឡាយណាចង គឺ កៀវថ្លក់ទុកវាងនាមកាយរូបកាយក្នុងបច្ចុប្បន្នភព និងនាមកាយរូបកាយក្នុងអនាគតភព ធម៌ទាំងនោះ ឈ្មោះថា **កាយគន្ថៈ** ។

ធម្មតាគ្រឿងចងដោយអាការកៀវថ្លក់ ដែលប្រើក្នុងន័យនៃគន្ថៈនេះ មិនមែនសំដៅយកការចងទុកធូរៗ ឆាយរបូតស្រួលៗនោះទេ គឺ សំដៅយកការចាក់ស្រេះ ក្រងធ្វាក់ទុកក្នុងលក្ខណៈកៀវថ្លក់ដូចជាច្រវាក់ដែលគ្មានកំណួច ព្រោះថាច្រវាក់ដែកនោះ ជាកងដែកដែលថ្លក់គ្នានិងគ្នា វណែងវណោង

ជាកម្រង មិនងាយរបូតពីគ្នាបានឡើយ ។

ដូច្នេះគន្ថៈមានន័យសេចក្ដី ជាគ្រឿងចាក់ស្រែះក្រងធ្វាក់ដោយអាការកៀវថ្ពក់គ្នា ដូចជាខ្សែប្រវាក់ដែក ។

ធម្មតា ប្រវាក់ដែកនោះជាកងកៀវថ្ពក់រណែងរណោងជាប់គ្នានិងគ្នាជាកម្រងយ៉ាងណា សភាវធម៌គឺលោភៈ ទោសៈ និងទិដ្ឋិទាំង ៣ នេះ ក៏ជាគ្រឿងចាក់ស្រែះក្រងធ្វាក់សត្វទុកក្នុងរវាងចុតិនិងបដិសន្ធិ ហើយបដិសន្ធិ និងចុតិ រណែងរណោងជាប់តគ្នា ជាកម្រងមិនងាយរបូតពីគ្នាបាន ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធព្រះអង្គទើបទ្រង់ត្រាស់ថាលោភៈ ទោសៈ ទិដ្ឋិ ទាំង៣នេះថាជា គន្ថៈ ហើយក្នុងនេះមានពាក្យ **កាយ** ប្រកបនេះ ក៏សម្ដែងដល់ធម៌ដែលជានាម-កាយនិង រូបកាយ បានដល់ សត្វទាំងឡាយនោះឯង ពោលគឺលោភៈ ទោសៈ ទិដ្ឋិ ជាគ្រឿងចាក់ស្រែះក្រងធ្វាក់សត្វទុកក្នុងរវាងចុតិនិងបដិសន្ធិឲ្យជាប់តៗគ្នាទៅ ដោយមិនអាចរួចផុតចាកវដ្ដទុក្ខបានឡើយ ។

## គន្ថៈមាន ៤ ប្រការ គឺ :

**១ - អភិជ្ឈាកាយគន្ថៈ** ជាធម្មជាតិដែលចាក់ស្រែះក្រងថ្នាក់នូវនាមកាយ និងរូបកាយទុកដោយអាការជាប់ជំពាក់ពេញចិត្តក្នុងកាមគុណអារម្មណ៍ អង្គធម៌បានដល់ លោភៈ-ចេតសិកក្នុងលោភមូលចិត្ត ៨ ។

**២ - ព្យាបាទកាយគន្ថៈ** ជាធម្មជាតិដែលចាក់ស្រែះក្រងថ្នាក់នូវនាមកាយ រូបកាយទុក ដោយអាការក្រោធខឹង គុំកួនអាក់អន់ចិត្ត អង្គធម៌បានដល់ ទោសចេតសិកដែលប្រកបក្នុងទោសមូលចិត្ត ២ ។

**៣ - សីលព្វតបរាមាសកាយគន្ថៈ** ជាធម្មជាតិដែលចាក់ស្រែះ ក្រងថ្នាក់នូវនាមកាយ-រូបកាយទុក ដោយអាការប្រកាន់ស្ទាបអង្អែលក្នុងសីលវត្ត ការបដិបត្តិខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិក ក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

**៤ - ឥទំសច្ចាភិនិវេសកាយគន្ថៈ** ជាធម្មជាតិដែលចាក់ស្រែះក្រងថ្នាក់នូវនាមកាយ-រូបកាយទុក ដោយអាការប្រកាន់ខ្ជាប់ក្នុងសេចក្ដីយល់ឃើញខុសរបស់ខ្លួនថាត្រូវ ក្នុង

សេចក្ដីយល់ឃើញត្រូវរបស់អ្នកដទៃថាខុស អង្គធម៌បានដល់ទិដ្ឋិចេតសិក ក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ គឺ សេចក្ដីយល់ឃើញខុស ដែលប្រកាន់ខ្ជាប់ទុកយ៉ាងមាំ ដូចជាសេចក្ដីយល់ឃើញរបស់បុគ្គលថ្នាក់គ្រូបាអាចារ្យ ។

គន្ថៈទាំង ៤ប្រការនេះ មានអង្គធម៌ត្រឹមតែ៣ ប៉ុណ្ណោះ គឺ លោភចេតសិក១ ទោសចេតសិក១ និងទិដ្ឋិចេតសិក១ ។

## ធម៌ដែលលះគន្ថៈ ៤

បញ្ញាក្នុងសោតាបត្តិមគ្គចិត្ត លះសីលព្វតបរាមាស-កាយគន្ថៈ និង ឥទំសច្ចាភិនិវេសកាយគន្ថៈ ។

បញ្ញាក្នុងអនាគាមិមគ្គចិត្ត លះព្យាបាទកាយគន្ថៈ ។

បញ្ញាក្នុងអរហត្តមគ្គចិត្ត លះអភិជ្ឈាកាយគន្ថៈ ។

## សេចក្ដីផ្សេងគ្នារវាងអភិជ្ឈានិងព្យាបាទ

ដែលជាមនោទុច្ចរិត និង អភិជ្ឈានិងព្យាបាទដែលជាគន្ថៈ

១ - **អភិជ្ឈាមនោទុច្ចរិត** ជាសេចក្ដីលោភយ៉ាងគ្រោតគ្រាត មានសភាពប្រាថ្នាចង់បានទ្រព្យសម្បត្តិរបស់អ្នក

ដទៃមកជារបស់ខ្លួនដែលមិនប្រកបដោយធម៌ ។

**២ - អភិជ្ឈាកាយគន្ថៈ** ជាសេចក្តីលោភយ៉ាងគ្រោតគ្រាត ទាំងយ៉ាងល្អិត ដែលទាក់ទងនឹងសេចក្តីប្រាថ្នាចង់បាន និងសេចក្តីពេញចិត្តក្នុងទ្រព្យសម្បត្តិរបស់អ្នកដទៃ ឬរបស់ខ្លួនឯង មិនប្រកបដោយធម៌ក្តី ដោយធម៌ក្តី គឺ សេចក្តីពេញចិត្តប្រាថ្នាចង់បាននោះ ចាត់ជាអភិជ្ឈាកាយគន្ថៈទាំងអស់ ។

**៣ - ព្យាបាទមនោទុច្ចរិត** បានដល់ ទោសៈយ៉ាងគ្រោតគ្រាត ដែលទាក់ទងនឹងសេចក្តីក្រោធ ចងពៀរ គិតប្រទូសរ៉ាយអ្នកដទៃ ដោយបំណងឲ្យគេបានដល់នូវសេចក្តីវិនាស ក្តៅក្រហាយផ្សេង ៗ ឬនឹងបន់ស្រន់ឲ្យអ្នកដែលខ្លួនស្អប់នោះដល់នូវសេចក្តីស្លាប់ ។

**៤ - ព្យាបាទកាយគន្ថៈ** បានដល់ ទោសៈយ៉ាងគ្រោត-គ្រាត ទាំងយ៉ាងល្អិត ដែលមានសភាពជាសេចក្តីមិនពេញចិត្ត មិនចូលចិត្ត ក្រោធ ខឹង ស្អប់ ខ្លាច ចងពៀរ សោយ-សោក អន់ចិត្ត តូចចិត្ត រហូតដល់ការធ្វើនូវទុច្ចរិតកម្មជាដើម សភាពទាំងអស់នេះចាត់ជាព្យាបាទកាយគន្ថៈទាំងអស់ ។

ដូច្នេះអភិជ្ឈា និងព្យាបាទដែលជាគន្ថៈ ទើបប្រព្រឹត្តទៅក្នុងសភាពទូលំទូលាយជាងអភិជ្ឈា និងព្យាបាទដែលជាមនោ-ទុច្ចរិត ។

## ៥ - ឧបាទាន

**ឧបាទាន** សំដៅដល់ ការប្រកាន់យកមាំក្នុងអារម្មណ៍ដោយអំណាចតណ្ហា និង ទិដ្ឋិដែលមានកម្លាំង ។

ពាក្យថា **ឧបាទាន** នេះកាលបែកស័ព្ទ ក៏បាន២ស័ព្ទ គឺ

**ឧប + អាទាន = ឧបាទាន**

**ឧប** សំដៅយកការមាំ **អាទាន** សំដៅយកការប្រកាន់ ។

រួមសេចក្តីមក **ឧបាទាន** សំដៅយកការប្រកាន់យកមាំក្នុងអារម្មណ៍ ។

ធម៌ដែលប្រកាន់យកមាំក្នុងអារម្មណ៍ ហៅថា **ឧបាទាន** ដូចមានវចនត្ថថា :-

**ឧបាទីយន្តីតិ = ឧបាទានានិ**

ប្រែថា ធម៌ទាំងឡាយណា រមែងប្រកាន់យកមាំក្នុងអារម្មណ៍

ធម៌ទាំងនោះឈ្មោះថា **ឧបាទាន** ។

**កុសំ អាទិយន្តិ អមុញ្ចគាហំ**

**គយ្ហន្តីតិ = ឧបាទានានិ**

ប្រែថា ធម៌ទាំងឡាយណាប្រកាន់យ៉ាងខ្ជាំងក្លា ធម៌ទាំងនោះឈ្មោះថា **ឧបាទាន** ។

**ឧបាទាន** នេះមានឧបមាដូចជា ពស់ដែលចាប់កញ្ចាញ់-ចេកឬកង្កែប រមែងខាំជាប់យ៉ាងណែនមិនព្រមលែងយ៉ាងណា សភាវធម៌គឺ លោភៈ ទិដ្ឋិ ក៏រមែងមានសភាពប្រកាន់មាំក្នុងអារម្មណ៍របស់ខ្លួនទុក មិនព្រមលែង ក៏យ៉ាងនោះដែរ ។

តាមន័យនៃបដិច្ចសមុប្បាទ **ឧបាទាន** កើតឡើងបានអាស្រ័យតណ្ហាជាបច្ច័យ ដូច្នេះតណ្ហាទើបជាចំណង់ប្រាថ្នាក្នុងអារម្មណ៍ដែលមិនទាន់មកដល់ ចំណែកឧបាទានជាការប្រកាន់យកមាំក្នុងអារម្មណ៍ដែលមកដល់ខ្លួនហើយ ដោយមិនព្រមលែងចោល ។

ឬន័យម្យ៉ាងទៀត

**តណ្ហា** ជាសេចក្តីត្រេកអរជាប់ចិត្តក្នុងអារម្មណ៍គ្រាដំបូង ។

**ឧបាទាន** ជាសេចក្តីត្រេកអរជាប់ចិត្តក្នុងអារម្មណ៍ដែលបានជួបហើយកប់ទុកនៅក្នុងចិត្តគំនិតមិនភ្លេច ។

ឬន័យម្យ៉ាងទៀត

**តណ្ហា** ប្រៀបដូចជាកូនឈើដែល ទើបតែដុះថ្មីៗ តែងដកចោលបានងាយបំផុត ។

**ឧបាទាន** ប្រៀបដូចជាដើមឈើនោះ ដុះលូតលាស់ធំហើយ ដែលដកចោលបានដោយលំបាក ព្រោះឫសកែវចាក់ជ្រៅមាំក្នុងដីហើយ ។

ដូច្នេះហើយ **ឧបាទាន** ទើបជាសេចក្តីប្រកាន់ក្នុងអារម្មណ៍ទុកយ៉ាងណែន យ៉ាងមាំជាង **តណ្ហា** ។

## ឧបាទានមាន ៤ ប្រការ គឺ :

**១ - កាមុបាទាន** គឺ ជាធម្មជាតិដែលប្រកាន់មាំក្នុងកាមគុណអារម្មណ៍ រហូតដល់ប្រកាន់មាំក្នុងភវសម្បត្តិ ដោយអំណាចតណ្ហាដ៏មានកម្លាំង អង្គធម៌បានដល់ លោភចេតសិកក្នុងលោភមូលចិត្ត ៨ ។

២ - **ទិដ្ឋុបាទាន** គឺជាធម្មជាតិដែលប្រកាន់មាំ ទុកក្នុងសេចក្ដីយល់ខុស ដែលផ្សេងអំពីសីលព្វតបរាមាសទិដ្ឋិ និង អត្តវាទទិដ្ឋិ អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

៣ - **សីលព្វតុបាទាន** គឺជាធម្មជាតិដែលប្រកាន់មាំ ក្នុងការបដិបត្តិខុសគិតថាការបដិបត្តិរបស់ខ្លួនអាចនាំឲ្យរួចផុតចាកទុក្ខបាន អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

៤ - **អត្តវាទុបាទាន** គឺជាធម្មជាតិដែលប្រកាន់មាំក្នុងរូបក្ខន្ធ-នាមក្ខន្ធ ថាជាតួខ្លួន ដោយអំណាចនៃសក្កាយទិដ្ឋិ អង្គធម៌បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត៤ ។

## ធម៌ដែលលះបង់ឧបាទាន ៤

**កាមុបាទាន** លះបង់បានដោយបញ្ញាក្នុងអរហត្តមគ្គចិត្ត។

**ទិដ្ឋុបាទាន** លះបង់បានដោយបញ្ញាក្នុងសោតាបត្តិមគ្គចិត្ត ។

**សីលព្វតុបាទាន** លះបង់បានដោយបញ្ញាក្នុងសោតា-បត្តិមគ្គចិត្ត ។

**អត្តវាទុបាទាន** លះបង់បានដោយបញ្ញាក្នុងសោតាបត្តិ-មគ្គចិត្ត ។

**សង្កេត :**

**កាមុបាទាន** សំដៅយករួមទាំងការប្រកាន់យកមាំក្នុងរូបភព និងអរូបភពផងដែរ ។

**ទិដ្ឋុបាទាន** កម្មស្សកតាញាណ រមែងលះបង់បានក្នុងកាលជាដំបូង ។

**អត្តវាទុបាទាន** វិបស្សនាញាណ រមែងលះបង់បានក្នុងកាលជាដំបូង ។

**វិបស្សនាបញ្ញា** ជាហេតុនៃការលះបង់ឧបាទានទាំងពួង ។

## ៦ - នីវរណៈ

**នីវរណៈ** នេះសំដៅយកធម៌ជាគ្រឿងហាមឃាត់ ឬជាគ្រឿងរាំងសេចក្ដីល្អ គឺ កុសលធម៌ផ្សេង ៗ ដែលនឹងកើត

ឡើង ត្រូវនីវរណធម៌ខាខាំងទប់មិនឲ្យកើតឡើង ក៏កើតឡើងមិនបាន និងកុសលធម៌បែបខ្លះ ដូចជាឈានកុសលជាដើម ដែលកំពុងកើត នីវរណធម៌នេះ ក៏ធ្វើឲ្យវិនាសសាបសូន្យទៅបាន ដូចមានវចនត្ថថា :

**ឈានាទិកំ និវារេន្តីតិ = នីវរណានិ**

ប្រែថា ធម៌ទាំងឡាយណាជារនាំងខិតយាំងរាំងសេចក្ដីល្អ មានឈានជាដើម មិនឲ្យកើតឡើង ធម៌ទាំងនោះ ឈ្មោះថា **នីវរណៈ** ។

ធម្មតាបុគ្គលទាំងឡាយភាគច្រើន តែងមិនត្រេកអរក្នុងការបំពេញទាន រក្សាសីល ចម្រើនភាវនាទេ ដែលជាយ៉ាងនេះ ក៏ព្រោះហេតុនៃអំណាចនីវរណធម៌ទុំះឯង ដែលបានដល់លោភៈ ទោសៈ ថីនមិទ្ធៈ ឧទ្ធច្ចៈ កុក្កុច្ចៈ វិចិកិច្ឆា និងមោហៈ ណាមួយ ឬច្រើននោះឯង ។ ជួនកាលខ្លះ ខណៈកំពុងតែធ្វើកុសលនោះ ក៏អាចកើតឡើងនូវសេចក្ដីថមថយកម្លាំងចិត្ត ធុញទ្រាន់ មិនសប្បាយត្រេកអរ បានធ្វើឲ្យសទ្ធាសតិបញ្ញាថយចុះវិនាស បាត់អស់រលីង នេះក៏គឺ ព្រោះតែ

អំណាចនៃថីនមិទ្ធនីវរណៈ កើតឡើងរារាំងនូវសេចក្ដីល្អមានសទ្ធាជាដើមនោះឯង ឬក៏ដោយអំណាចនៃកាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈយ៉ាងគ្រោតគ្រាត កើតឡើងដល់ឈានលាភីបុគ្គល ក៏ធ្វើឲ្យឈានបានសម្រេចហើយនោះ វិនាសបាត់បង់ទៅវិញ រហូតដល់មិនអាចតាំងនៅក្នុងឈានសមាបត្តិបានទៀតផង ។

ដូច្នេះ **នីវរណធម៌** ទើបជាធម៌ដែលរារាំង ខាខាំងនូវកុសលធម៌ទាំងឡាយមិនឲ្យកើត ពោលដោយចំពោះជាគ្រឿងរារាំងនូវឈាន មគ្គ ផល អភិញ្ញាសមាបត្តិ ។

## នីវរណធម៌មាន ៦ ប្រការ គឺ

**១ - កាមច្ឆន្ទនីវរណៈ** ធម្មជាតិដែលជាគ្រឿងរារាំងនូវសេចក្ដីល្អ គឺ សេចក្ដីពេញចិត្តត្រេកអរក្នុងកាមគុណ-អារម្មណ៍ រមែងខាខាំងនូវសមាធិ ដែលនឹងឲ្យចូលសម្រេចដល់ឈានជាដើម អន្តធម៌បានដល់ លោភចេតសិកក្នុងលោភ-មូលចិត្ត៨ ។

**២ - ព្យាបាទនីវរណៈ** ធម្មជាតិដែលជាគ្រឿងរារាំងនូវសេចក្ដីល្អ គឺ សេចក្ដីក្រោធ រមែងកម្ចាត់បង់នូវបីតិដែលនឹងឲ្យចូលសម្រេចដល់ឈានជាដើម អង្គធម៌បានដល់ ទោស-ចេតសិក ក្នុងទោសមូលចិត្ត ២ ។

**៣ - ថីនមិទ្ធនីវរណៈ** ធម្មជាតិដែលជាគ្រឿងរារាំងនូវសេចក្ដីល្អ គឺ សេចក្ដីងោកងុយរួញរា រមែងធ្វើឲ្យបាត់បង់នូវវិតក្កដែលជាអង្គឧបការដល់ឈានជាដើម អង្គធម៌បានដល់ ថីនចេតសិក និង មិទ្ធចេតសិក ក្នុងអកុសលសសង្ខារិកចិត្ត ៥ ដួង ។

**៤ - ឧទ្ធច្ចកុក្កុច្ចនីវរណៈ** ធម្មជាតិដែលជាគ្រឿងរារាំងនូវសេចក្ដីល្អ គឺ សេចក្ដីអណ្ដែតអណ្ដូងស្ដាយក្រោយ រមែងធ្វើឲ្យបាត់បង់នូវសេចក្ដីសុខ ដែលឧបការដល់ឈានកុសលជាដើម អង្គធម៌បានដល់ ឧទ្ធច្ចចេតសិក ក្នុងអកុសលចិត្ត១២ និង កុក្កុច្ចចេតសិកក្នុងទោសមូលចិត្ត ២ ។

**៥ - វិចិកិច្ឆានីវរណៈ** ធម្មជាតិដែលជាគ្រឿងរារាំងនូវសេចក្ដីល្អ គឺ សេចក្ដីសង្ស័យស្ទាក់ស្ទើរក្នុងវត្ថុដែលគួរជឿ

រមែងកម្ចាត់បង់នូវវិចារដែលពិចារណាអារម្មណ៍ ឈានជាដើម អង្គធម៌បានដល់ វិចិកិច្ឆាចេតសិកក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត១ ។

**៦ - អវិជ្ជានីវរណៈ** ធម្មជាតិដែលជាគ្រឿងរារាំងនូវសេចក្តីល្អ គឺ សេចក្តីវង្វេងល្ងង់ខ្លៅ ដែលបិទបាំងមិនឲ្យដឹងនូវសភាវធម៌តាមសេចក្តីពិត អង្គធម៌បានដល់ មោហចេតសិកក្នុងអកុសលចិត្ត ១២ ។

ក្នុងនីវរណៈ ៦ ប្រការនេះ កាលពោលដោយអង្គធម៌ហើយ មាន ៨ ប្រការ គឺ :

លោភចេតសិក ទោសចេតសិក ថីនចេតសិក មិទ្ធ-ចេតសិក ឧទ្ធច្ចចេតសិក កុក្កុច្ចចេតសិក វិចិកិច្ឆាចេតសិក មោហចេតសិក ។

ចំណែកថីនចេតសិក និងមិទ្ធចេតសិក ទាំង២ នេះដែលចាត់ជានីវរណៈតែមួយជាមួយគ្នា ព្រោះជាសហកទាចិចេតសិក គឺត្រូវកើតព្រមនឹងអកុសលសសង្ខារិកចិត្តជាមួយគ្នា បើពោលដោយកិច្ច តែងធ្វើឲ្យចិត្តនិងចេតសិករួញរាងោកងក់ចាកពីអារម្មណ៍ដូចគ្នា ជាហេតុនៃកោសជ្ជៈ គឺសេចក្តីខ្ជិលដូចគ្នា និងបើពោល

ដោយបដិបក្ខធម៌ គឺមានវីរិយចេតសិកជាបដិបក្ខធម៌តែម្យ៉ាង រួមជាមួយគ្នា ។

ចំពោះឧទ្ធច្ចចេតសិកនិងកុក្កុច្ចចេតសិក ចាត់ជានីវរណៈតែមួយជាមួយគ្នា បើពោលដោយកិច្ច គឺ ធ្វើមិនឲ្យស្ងប់ បើពោលដោយបច្ច័យ ជាហេតុឲ្យមានព្យសនៈ ៥ ប្រការ ។ បើពោលដោយបដិបក្ខធម៌ ជាធម៌បដិបក្ខនឹងសោមនស្សវេទនាគឺសេចក្ដីសុខនៃចិត្ត ដែលជាហេតុធ្វើឲ្យសម្រេចដល់ អប្បនាភាវនាដូចគ្នា ។

នីវរណធម៌ដែលជាគ្រឿងរាំងនូវឈាន ក្នុងការចម្រើនសមថភាវនានោះ មានត្រឹមតែ ៥ ប្រការប៉ុណ្ណោះ គឺ :

១ - កាមច្ឆន្ទនីវរណៈ

២ - ព្យាបាទនីវរណៈ

៣ - ថីនមិទ្ធនីវរណៈ

៤ - ឧទ្ធច្ចកុក្កុច្ចនីវរណៈ

៥ - វិចិកិច្ឆានីវរណៈ

ចំណែកអវិជ្ជានីវរណៈ មិនមែនជាគ្រឿងរាំងនូវឈាន

ណាមួយនោះទេ ព្រោះឈានដោយច្រើន អាស្រ័យនូវបញ្ញត្តិអារម្មណ៍ឯចំណែកការចម្រើនវិបស្សនាកម្មដ្ឋាន ដើម្បីឲ្យបានសម្រេចមគ្គ ផល និព្វាននោះ គឺ ត្រូវតែអាស្រ័យនូវបញ្ញា គឺសម្មាទិដ្ឋិជាប្រការសំខាន់ ដូច្នោះហើយ ទើបបានជាពោលថា អវិជ្ជានីវរណៈប៉ុណ្ណោះជាគ្រឿងរារាំងនូវមគ្គ ផល និព្វានដោយពិត ។

ចំណែកនីវរណៈ ៥ ប្រការ ដែលជាគ្រឿងរារាំងឈាននោះ ក្នុងការចម្រើនវិបស្សនា រមែងចាត់ជាអារម្មណ៍របស់សតិប្បដ្ឋាន ក្នុងធម្មានុបស្សនាសតិបដ្ឋាននៃនីវរណបព្វវិញ ដូចជាកំណត់នាមពេញចិត្ត នាមមិនពេញចិត្ត នាមអណ្តែត-អណ្តូង នាមងងុយងោកងក់ និងនាមសង្ស័យ ដើម្បីញ៉ាំងវិបស្សនាញាណឲ្យកើត និងឲ្យបានសម្រេចដល់ មគ្គ ផល និព្វាន ព្រោះហេតុនោះ នីវរណៈ ៥ ទើបមិនជាគ្រឿងរារាំងមគ្គ ផល និព្វាន ពិតប្រាកដបានទេ ។

ប៉ុន្តែយ៉ាងណាក៏ដោយ បើអវិជ្ជាមានកម្លាំងច្រើនធ្វើឲ្យអ្នកបដិបត្តិភ្លេចភ្លាំងស្មារតីជានិច្ច ឬ បញ្ញាទន់ខ្សោយ ក៏មិន

អាចពិចារណានូវនីវរណៈ៥ ដែលកំពុងប្រាកដនោះបានឡើយ កាលបើជាយ៉ាងនេះ ក៏ពោលបានថា នីវរណធម៌ទាំង ៦ប្រការ ជាគ្រឿងរាំងមគ្គ ផល និព្វានបាន ។

សរុបសេចក្តី នីវរណធម៌ដែលជាគ្រឿងរាំងឈាននេះ មាន ៥ ប្រការ ( វៀរអវិជ្ជានីវរណៈ ) ចំណែកនីវរណធម៌ ដែលជាគ្រឿងរាំងមគ្គ ផល និព្វាននោះ មាន ៦ ប្រការ ។

នីវរណធម៌ជាបរិយុដ្ឋានកិលេស គឺកិលេសយ៉ាងកណ្តាល ធ្វើការសង្កត់សង្កិនបានដោយសមថភាវនា ប៉ុន្តែបើនឹងប្រហារ កិលេសនីវរណៈឲ្យដាច់ជាសមុច្ឆេទទៅបាន ត្រូវអាស្រ័យការ ចម្រើននូវវិបស្សនារហូតដល់បានសម្រេច មគ្គ ផល និព្វាន ទើបប្រហារកិលេសបានពិតប្រាកដ ។

## ធម៌ដែលលះនីវរណៈ ៦

- **បញ្ញា** ក្នុងសោតាបត្តិមគ្គចិត្តលះ វិចិកិច្ឆានីវរណៈ និង កុក្កុច្ចនីវរណៈ ។

- **បញ្ញា** ក្នុងអនាគាមិមគ្គចិត្តលះ កាមច្ឆន្ទនីវរណៈ និង ព្យាបាទនីវរណៈ ។

- **បញ្ញា** ក្នុងអរហត្តមគ្គចិត្ត លះនីវរណៈដែលនៅសល់ទាំងអស់ ។

## - សង្កេត

អាការស្វាបរោកកន្ទុយ ជាធម៌ប្រចាំកាយរបស់សត្វម្នាក់ៗ ហៅថា **កាយានុគតធម៌** មាន ១០ ប្រការ គឺ :

១ - **សីត** បានដល់ សម្ផស្សត្រជាក់ ។

២ - **ឧណ្ហ** បានដល់ សម្ផស្សក្តៅ ។

៣ - **ជិឃច្ឆា** បានដល់ ឃ្លាន ។

៤ - **បិបាស** បានដល់ ស្រេក ។

៥ - **ឧច្ចារ** បានដល់ បន្ទោបង់លាមក ។

៦ - **បស្សាវ** បានដល់ បន្ទោបង់ទឹកមូត្រ ។

៧ - **ថីនមិទ្ធ** បានដល់ ការងងុយងោកងក់ ដេកលក់ ។

៨ - **ជរា** បានដល់ ចាស់ ។

៩ - **ព្យាធិ** បានដល់ ឈឺ ។

១០ - **មរណ** បានដល់ ស្លាប់ ។

ថីនមិទ្ធៈ ដែលជាការងងុយងោកងក់នោះ ថីនមិទ្ធៈដែលជាកិលេសនីវរណៈ រមែងកើតឡើងបានចំពោះបុថុជ្ជន និងសេក្ខបុគ្គល ។

ចំណែកព្រះអរហន្តខីណាស្រព អ្នកអស់អាសវក្កិលេសហើយ ការដេកសឹងលក់មិនប្រព្រឹត្តទៅជាមួយថីនមិទ្ធកិលេសទេ គង់មានតែការដេកលក់ ដែលជាការចាំបាច់របស់ករវត្តកិច្ច គឺ ជាធម៌ប្រចាំកាយប៉ុណ្ណោះ ។

## ៧ - អនុស័យ

**អនុស័យ** ជាឈ្មោះរបស់កិលេសដ៏យ៉ាងល្អិតម្យ៉ាងដែលដេកសំងំនៅក្នុងខន្ធសន្តានរបស់សត្វទាំងឡាយ ។ ដរាបដែលនៅមិនទាន់បានសម្រេចជាព្រះអរហន្តទេ អនុស័យនេះ ក៏នឹងនៅមានជាប្រចាំក្នុងខន្ធសន្តានជារៀយៗតទៅ ព្រោះហេតុនោះ អនុស័យទើបជាធម្មជាតិដែលជ្រកសំងំ មិនចេញបង្ហាញដើម្បីឲ្យអ្នកណាមួយបានឃើញ បានប្រចក្សឡើយវៀរលែងតែព្រះ-សម្មាសម្ពុទ្ធមួយព្រះអង្គប៉ុណ្ណោះ ដែលព្រះអង្គទ្រង់អាចដឹងអំពីអនុស័យរបស់សត្វទាំងឡាយបាន ។

ធម្មតាអនុស័យកិលេសនោះ ជាធម្មជាតិល្អិតជ្រកសំងំនៅជាប្រចាំក្នុងខន្ធសន្តាន មិនបញ្ចេញបង្ហាញឲ្យប្រាកដទៅតាមទ្វារណាមួយឡើយ ។ លុះកាលណាមានអារម្មណ៍ផ្សេង ៗ មកប៉ះខ្ទប់តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្តហើយ អនុស័យដែលដេកសំងំនៅនោះ ក៏ប្រែសភាពជាបរិយុដ្ឋានកិលេស គឺ កិលេសយ៉ាងកណ្តាល ប្រាកដឡើងតាមផ្លូវចិត្ត ជាសេចក្តីត្រេកអរ-មិនត្រេកអរចំពោះអារម្មណ៍ដែលប្រសព្វនោះៗ ។ ហើយប្រសិនបើបរិយុដ្ឋានកិលេសនេះមានកម្លាំងខ្លាំងឡើង ក៏នឹងជាបច្ច័យដល់វីតិក្កមកិលេស គឺកិលេសគ្រោតគ្រាតប្រាកដឡើងតាមផ្លូវកាយ តាមផ្លូវវាចាជាទុច្ចរិតផ្សេងៗទៅ ។

បរិយុដ្ឋានកិលេស និងវីតិក្កមកិលេសទាំង ២ ប្រភេទនេះ មិនហៅថា អនុស័យកិលេសទេ ប៉ុន្តែបរិយុដ្ឋានកិលេសកើតអំពីអនុស័យកិលេស និង វីតិក្កមកិលេសកើតអំពី បរិ-យុដ្ឋានកិលេស ដែលជាបច្ច័យឧបត្ថម្ភដល់គ្នានិងគ្នាទៅយ៉ាងនេះឯង ។

ដោយហេតុនេះ អនុស័យកិលេស ទើបជាកិលេសម្យ៉ាង ដែលមានសភាពល្អិត ដេកជ្រកសំងំស្ងប់នៅក្នុងខន្ធសន្តាននៃសត្វទាំងឡាយ ដូចមានវចនត្ថថា :-

**សន្តានេ អនុសេន្តីតិ = អនុសយា**

ប្រែថា ធម៌ទាំងឡាយណា រមែងដេកសំងំនៅជារឿយ ៗ ក្នុងសន្តាននៃរូប-នាម ធម៌ទាំងនោះឈ្មោះថា **អនុស័យ** ។ ធម៌ដែលដេកសំងំនោះ សំដៅយកដែលលះបង់មិនទាន់បាននៅឡើយ ។

ម្យ៉ាងទៀតថា :-

**អនុរូបំ ការណំ លភិត្វា សេន្តិ**

**ឧប្បជ្ជន្តីតិ = អនុសយា**

ប្រែថា ធម៌ទាំងឡាយណា កាលបើបានហេតុសមគួរហើយ រមែងកើតឡើងបាន ធម៌ទាំងនោះឈ្មោះថា **អនុស័យ** ។

ឧបមាអនុស័យកិលេស បរិយុដ្ឋានកិលេសនិងវីតិក្កមកិលេស ដូចជាឈើគូសក្នុងប្រអប់ យកឈើគូសមួយដើមទៅគូសត្រង់ផ្នែកចំហៀងនៃប្រអប់ភ្លើងក៏ប្រាកដឡើង។ ហើយ

កាលយកភ្លើងនោះទៅអុជនឹងវត្ថុណា ៗ ដូចជាចង្កៀងជាដើម ភ្លើងក៏ឆេះវត្ថុនោះ គឺ ចង្កៀងនោះៗ ។

អនុស័យកិលេស ប្រៀបបីដូចជាធាតុប្រេងដែលមាននៅត្រង់ក្បាលឈើគូសនោះ ។ អារម្មណ៍ផ្សេងៗ ដែលមកប៉ះខ្ទប់ត្រង់ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដូចជាការយកឈើគូសដើមណាមួយទៅគូសត្រង់ចំហៀងប្រអប់ដូច្នោះ ។

***បរិយុដ្ឋានកិលេស*** ដូចជាភ្លើងដែលប្រាកដឡើងត្រង់ក្បាលឈើគូសនោះ កាលនាំទៅអុជនឹងវត្ថុដទៃដូចជាចង្កៀងជាដើម ចង្កៀងក៏ឆេះឡើង ភ្លើងដែលឆេះនឹងចង្កៀងនោះប្រៀបបីដូចជា ***វីតិក្កមកិលេស*** យ៉ាងនោះឯង ។

## ធម៌ដែលលះកិលេសទាំង ៣ នេះ គឺ

- ***សីល*** ប្រហារ វីតិក្កមកិលេស ។
- ***សមាធិ*** ប្រហារ បរិយុដ្ឋានកិលេស ។
- ***បញ្ញា*** ( ក្នុងមគ្គចិត្ត ) ប្រហារអនុស័យកិលេស ។

## អនុស័យកិលេសមាន ៧ ប្រការ គឺ :

**១ - កាមរាគានុស័យ** ធម្មជាតិដែលជាសេចក្តីត្រេកអរ ជាប់ចិត្តក្នុងកាមគុណអារម្មណ៍ ដែលដេកសំងំនៅក្នុងខន្ធសន្តាន ។ កាលប៉ះខ្ទប់អារម្មណ៍ ក៏ប្រែសភាពទៅជាបរិយុដ្ឋានកិលេសហើយ ក៏មានសភាពជាលោភចេតសិកដែលប្រកបជាមួយលោភមូលចិត្ត ៨ ។

**២ - ភវរាគានុស័យ** ធម្មជាតិដែលជាសេចក្តីត្រេកអរ ជាប់ចិត្តក្នុងអត្តភាពរបស់ខ្លួន ជាប់ចិត្តក្នុងរូបភព អរូបភព ឬ រូបឈាន អរូបឈាន ដែលដេកសំងំនៅក្នុងខន្ធសន្តាន ។ កាលប៉ះខ្ទប់អារម្មណ៍ ប្រែសភាពទៅជាបរិយុដ្ឋានកិលេសហើយ បានដល់ លោភចេតសិកដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ។

៣ - **បដិឃានុស័យ** ធម្មជាតិដែលជាសេចក្តីមិនពេញចិត្តក្នុងអារម្មណ៍ដែលដេកសំងំនៅក្នុងខន្ធសន្តាន។ កាលប៉ះខ្ទប់អារម្មណ៍ ប្រែសភាពទៅជាបរិយុដ្ឋានកិលេសហើយ បានដល់ ទោសចេតសិកដែលប្រកបក្នុងទោសមូលចិត្ត ២ ។

៤ - **មានានុស័យ** ធម្មជាតិដែលជាសេចក្តីក្រអឺតលើកកម្ពស់ វាយឫកដែលដេកសំងំនៅក្នុងខន្ធសន្តាន ។ កាលប៉ះខ្ទប់អារម្មណ៍ ប្រែសភាពទៅជាបរិយុដ្ឋានកិលេសហើយ បានដល់ មានចេតសិកដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត៤ ។

៥ - **ទិដ្ឋានុស័យ** ធម្មជាតិដែលជាគ្រឿងយល់ឃើញខុសដែលដេកសំងំនៅក្នុងខន្ធសន្តាន ។ កាលប៉ះខ្ទប់អារម្មណ៍ប្រែ សភាពទៅជាបរិយុដ្ឋានកិលេសហើយ បានដល់ ទិដ្ឋិ-ចេតសិក ដែលប្រកបក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

៦ - **វិចិកិច្ឆានុស័យ** ធម្មជាតិដែលជាសេចក្តីសង្ស័យស្ទើរស្ទាក់ក្នុងវត្ថុដែលគួរជឿ ដែលដេកត្រាំសំងំនៅក្នុងខន្ធ-សន្តាន កាលប៉ះខ្ទប់អារម្មណ៍ ក៏ប្រែសភាពទៅជាបរិយុដ្ឋាន-កិលេស បានដល់ វិចិកិច្ឆាចេតសិកដែលប្រកបក្នុងវិចិកិច្ឆា-សម្បយុត្តចិត្ត ១ ។

៧ - **អវិជ្ជានុស័យ** ធម្មជាតិដែលជាសេចក្តីវង្វេងល្ងង់ខ្លៅ មិនដឹងសភាវធម៌តាមសេចក្តីពិត ដែលដេកសំងំនៅក្នុងខន្ធសន្តាន កាលប៉ះខ្ទប់អារម្មណ៍ ក៏ប្រែសភាពជាបរិយុដ្ឋានកិលេស

ហើយ បានដល់ មោហចេតសិកដែលប្រកបនៅក្នុងអកុសលចិត្ត១២ ។

អនុស័យ ៧ ប្រការនេះ កាលប្រែសភាពជាបរិយុដ្ឋានកិលេសហើយ មានប្រភេទជាអង្គធម៌ ៦ យ៉ាង គឺ :

**លោភចេតសិក ទោសចេតសិក មានចេតសិក ទិដ្ឋិចេតសិក វិចិកិច្ឆាចេតសិក មោហចេតសិក ។**

## ធម៌ដែលលះអនុស័យ ៧

- **បញ្ញា** ក្នុងសោតាបត្តិមគ្គចិត្តលះ ទិដ្ឋានុស័យ និង វិចិកិច្ឆានុស័យ ។
- **បញ្ញា** ក្នុងអនាគាមិមគ្គចិត្តលះ កាមរាគានុស័យ និង បដិឃានុស័យ ។
- **បញ្ញា** ក្នុងអរហត្តមគ្គចិត្តលះ ភវរាគានុស័យ មានានុស័យ និងអវិជ្ជានុស័យ ។

## ៨ - សំយោជនៈ

សំយោជនៈ សំដៅយកធម្មជាតិដែលជាគ្រឿងចងសត្វទាំងឡាយឲ្យជាប់នៅក្នុងវដ្តទុក្ខ ដូចជាខ្សែចងលាមសត្វទុកជាប់

នឹងបង្គោលមិនឲ្យរួចរបូតទៅបាន ដូចមានវចនត្ថសម្តែងថា :

**សំយោជេន្តិ ពន្ធន្តីតិ = សំយោជនានិ**

ប្រែថា ធម៌ឯណា រមែងចងសត្វទាំងឡាយទុក ធម៌ទាំងនោះឈ្មោះថា **សំយោជនៈ** ។

ម្យ៉ាងទៀត **ទូរគតស្សាបិ អាកឌ្ឍនតោ និស្សរិតុំ អប្បទានាវសេន ពន្ធនំ = សំយោជនំ**

ប្រែថា ការចងសត្វឲ្យជាប់នៅក្នុងវដ្តទុក្ខដោយអំណាចមិនឲ្យចេញផុតចាកទុក្ខក្នុងវដ្តបាន ដោយការទាញកន្ត្រាក់ ឬរួបរឹតសត្វដែលនៅក្នុងទីឆ្ងាយៗឲ្យចុះមកឈ្មោះថា សំយោជនៈ។

ម្យ៉ាងទៀត **ពន្ធនាការ កាមម្ហិសំយោជនេន វដ្ឍុយាគីវាយ ពន្ធិតា សត្តា ន សក្កោន្តិ ចសេពុំ** ។

ប្រែថា សត្វទាំងឡាយដែលត្រូវខ្សែ គឺ សំយោជនៈចងទុកក្នុងកាមគុណ៥ ដែលប្រៀបបីដូចជាគុក ទើបមិនអាចនឹងគេចទៅឲ្យរួចផុតបានឡើយ ។

តាមធម្មតា ក្នុងសន្តានរបស់បុថុជ្ជនទាំងឡាយ រមែងមានធម្មជាតិម្យ៉ាង ដែលប្រៀបបីដូចជាខ្សែ ១០ សរសៃដែល

ចងរួបរឹតសត្វទុក មិនឲ្យរបូតរួចផុតអំពីកងទុក្ខបាន គឺធ្វើឲ្យអន្ទោលត្រាច់រង្គាត់ស្វាប់កើតនៅក្នុងតែវដ្តទុក្ខ ។

ខ្សែ ១០ សរសៃទាំងនោះ គឺ សំយោជនៈ នោះឯង ។

ប្រសិនបើ សរសៃខ្សែណាមួយតឹងហើយ សំយោជនៈសរសៃនោះ ក៏នឹងទាញនាំយកសត្វនោះទៅកើតក្នុងភូមិដែលជាប់ទាក់ទង នឹងសំយោជនៈនោះៗ តាមអជ្ឈាស្រ័យកម្មដែលសត្វទាំងនោះបានសន្សំទុកមក ។

សំយោជនៈនេះ ជួនកាលក៏ប្រើជាសញ្ញោជនៈ មានន័យថា គឺ គ្រឿងចងសត្វទុក ។

ការសម្តែងសញ្ញោជនធម៌ មាន២ន័យ គឺ តាមន័យនៃព្រះអភិធម្ម១ និងតាមន័យនៃព្រះសូត្រ១ ។ ប៉ុន្តែទាំង ២ន័យនេះ នីមួយៗ ក៏មានចំនួនសំយោជនៈ ១០ ប្រការ ស្មើៗគ្នា ហើយក្នុងសំយោជនៈ១០ ប្រការនេះ ចែកចេញជា២ពួក គឺ :

១ - **ឱរម្ភាគិយសំយោជនៈ** ឬ កាមសំយោជនៈ បានដល់ សំយោជនៈដែលចងរួបរឹតទាញសត្វទុកក្នុងភូមិខាងក្រោម គឺ កាមភូមិ ។

**២ - ឧទ្ធម្ភាគិយសំយោជនៈ ឬ ភវសំយោជនៈ** បានដល់ សំយោជនៈដែលចងរួបរឹតសត្វទុក ក្នុងភូមិខាងលើ គឺ រូបភូមិ និង អរូបភូមិ ។

## ចំណែកសំយោជនៈ ១០
## តាមន័យនៃព្រះសូត្រសុត្តន្តន័យ

**១ - កាមរាគសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលជាប់ជំពាក់នៅក្នុងកាមគុណអារម្មណ៍ អង្គធម៌បានដល់ លោភចេតសិកដែលប្រកបក្នុងលោភមូលចិត្ត៨។

**២ - រូបរាគសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលជាប់ជំពាក់នៅក្នុងរូបភព ឬរូបឈាន អង្គធម៌ បានដល់ លោភចេតសិកដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត៤។

**៣ - អរូបរាគសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលជាប់ជំពាក់នៅក្នុងអរូបភព ឬអរូបឈាន អង្គធម៌ បានដល់ លោភចេតសិកដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត៤ ។

**៤ - បដិឃសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលក្រោធខឹង អង្គធម៌បានដល់ ទោសចេតសិក ដែលប្រកបក្នុងទោសមូលចិត្ត ២ ។

**៥ - ទិដ្ឋិសំយោជនៈ** ធម្មជាតិដែលចងសត្វទុកដោយ អាការដែលយល់ឃើញខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិក ដែលប្រកបក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

**៦ - មានសំយោជនៈ** ធម្មជាតិដែលចងសត្វទុកដោយ អាការដែលក្រអឺត លើកកម្ពស់ វាយឫក អង្គធម៌បានដល់ មានចេតសិក ដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ។

**៧ - សីលព្វតបរាមាសសំយោជនៈ** ធម្មជាតិដែល ចងសត្វទុកដោយអាការដែលស្ទាបអង្អែលក្នុងវត្តប្រតិបត្តិខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិក ដែលប្រកបក្នុងទិដ្ឋិគតសម្ប-យុត្តចិត្ត ៤ ។

**៨ - វិចិកិច្ឆាសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលសង្ស័យស្ទើរស្ទាក់ក្នុងវត្ថុដែលគួរជឿ អង្គធម៌បានដល់ វិចិកិច្ឆាចេតសិកដែលប្រកបក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត១ ។

**៩- ឧទ្ធច្ចសំយោជនៈ** ធម្មជាតិដែលចងសត្វទុកដោយអាការដែលរាយមាយ អណ្តែតអណ្តូងអន្ធធម៌បានដល់ ឧទ្ធច្ចចេតសិក ដែលប្រកបក្នុងអកុសលចិត្ត ១២ ។

**១០ - អវិជ្ជាសំយោជនៈ** ធម្មជាតិដែលចងសត្វទុកដោយអាការវង្វេង ល្ងង់ខ្លៅ មិនដឹងសភាវធម៌តាមសេចក្តីពិត អន្ធធម៌បានដល់ មោហចេតសិកដែលប្រកបក្នុងអកុសលចិត្ត១២ ។

## ឱរម្ភាគិយសំយោជនៈ ៥ ប្រការ

១ - កាមសំយោជនៈ ២ - បដិឃសំយោជនៈ

៣ - ទិដ្ឋិសំយោជនៈ ៤-សីលព្វតបរាមាសសំយោជនៈ

៥ - វិចិកិច្ឆាសំយោជនៈ

## ឧទ្ធម្ភាគិយសំយោជនៈ ៥ ប្រការ

១ -រូបរាគសំយោជនៈ ២ -អរូបរាគសំយោជនៈ

៣ - មានសំយោជនៈ ៤ - ឧទ្ធច្ចសំយោជនៈ

៥ - អវិជ្ជាសំយោជនៈ

ធម្មតាបុថុជ្ជនទាំងឡាយដែលមិនបានឈាន កាមរាគសំយោជនៈ

រមែងនឹងតាំងជាប្រចាំនៅជានិច្ច និងបើបានធ្វើទុច្ចរិតកម្មទុក ច្រើនទៀតផង បដិឃសំយោជនៈយ៉ាងគ្រោតគ្រាត ទិដ្ឋិសំយោជនៈ និងវិចិកិច្ឆាសំយោជនៈទាំង៣យ៉ាងនេះ ក៏នឹងមានឱកាសរឹតតឹង ឡើង ហើយនាំអ្នកនោះទៅកាន់អបាយភូមិបាន ។

ចំណែកសីលព្វតបរាមាសសំយោជនៈ នោះមិនបានប្រាកដ ដល់បុគ្គលទូទៅទេ តែប្រសិនបើប្រាកដតឹងឡើងដល់បុគ្គលណា ក៏អាចនាំអ្នកនោះទៅកាន់អបាយភូមិបានដូចគ្នា ។

ប្រសិនបើបុគ្គលនោះ បានធ្វើសុចរិតកម្មជាចំណែកច្រើន បដិឃសំយោជនៈយ៉ាងសាមញ្ញ (មិននាំទៅកាន់អបាយ) និង សក្កាយទិដ្ឋិសំយោជនៈទាំង២នេះ មានឱកាសរឹតតឹងបានហើយ ក៏ទាញបុគ្គលនោះ នាំឲ្យកើតជាមនុស្ស ឬជាទេវតា ។

ចំណែក មិច្ឆាទិដ្ឋិ សីលព្វតបរាមាស វិចិកិច្ឆាសំយោជនៈ ទាំង៣នេះ មិនមានឱកាសរឹតតឹងបានក្នុងការប្រព្រឹត្តិនូវកុសល ឡើយ ។

ចំពោះបុថុជ្ជនដែលបានឈាន កាមរាគសំយោជនៈបដិឃ- សំយោជនៈ និងសីលព្វតបរាមាសសំយោជនៈទាំង៣ប្រការនេះ

មិនមានឱកាសនឹងកើតតឹងបានទេ ។

ឧទ្ធម្ភាគិយសំយោជនៈ គឺ រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ និងអវិជ្ជាសំយោជនៈប៉ុណ្ណោះ ដែលមានឱកាសកើតតឹងបាន ស្រេចតែរូបឈាន និងអរូបឈានដែលខ្លួនបាន ដោយហេតុនេះ ឈានលាភីបុគ្គល កាលស្លាប់ពីកាមភូមិទៅកើតក្នុងរូបភូមិ ឬអរូបភូមិ តាមសមគួរដល់ឈាន ។

ប៉ុន្តែបុថុជ្ជនដែលទៅកើតជាព្រហ្មនេះ នៅមិនទាន់បានប្រហារកាមរាគសំយោជនៈ បដិឃសំយោជនៈ ឲ្យជាសមុច្ឆេទនៅឡើយទេ គ្រាន់តែប្រហារដោយការគ្របសង្កត់ទុកដោយអំណាចរបស់ឈានប៉ុណ្ណោះ ដូច្នោះកាលព្រហ្មអង្គណាវិនាសចាកឈាន បន្ទាប់ពីស្លាប់ទៅក៏នឹងកើតជាព្រហ្មតទៅទៀតមិនបាន គឺត្រូវតែមកកើតក្នុងកាមភូមិជាមនុស្ស ឬក៏ជាទេវតាវិញ ដែលជាយ៉ាងនេះនុ៎ះ ក៏ដោយអំណាចរបស់កាមរាគ-សំយោជនៈ បដិឃសំយោជនៈដែលមានចងនៅក្នុងខន្ធសន្តានរបស់ខ្លួនឯងជាអ្នកទាញកើតតឹងចុះមកដោយ **ឱរម្ភាគិយសំយោជនៈ**។

ចំណែកព្រះអរិយបុគ្គល ដែលសម្រេចជាព្រះសោតាបន្ន

ឬព្រះសកទាគាមិបុគ្គលនោះ ប្រហារទិដ្ឋិ វិចិកិច្ឆា សីលព្វត-បរាមាសសំយោជនៈទាំង៣នេះដាច់ជាសមុច្ឆេទហើយ ទើបផុតស្រឡះចាកការទាញរឹតតឹងទៅកាន់ **ហេដ្ឋិមសង្សារ** គឺ អបាយភូមិទាំង៤ ប៉ុន្តែនៅមិនទាន់រួចផុតអំពី **មជ្ឈិមសង្សារ** គឺមនុស្សភូមិទេវភូមិ និង**ឧបរិមសង្សារ** គឺ រូបភូមិ អរូបភូមិ ដែលជាភូមិខាងលើបានឡើយ ។ ទាំងនេះ ក៏ព្រោះនៅមានសំយោជនៈដែលសល់ ៧ ទៀតនៅក្នុងខន្ធសន្តាន ។

លុះកាលណាសម្រេចជាព្រះអនាគាមី ក៏នឹងបានប្រហារកាមរាគសំយោជនៈ និងបដិឃសំយោជនៈទាំងពីរនេះបានដាច់ជាសមុច្ឆេទថែមទៀត ក៏ជាការកាត់ផ្តាច់នូវមជ្ឈិមសង្សារដាច់ជាសមុច្ឆេទ ដូច្នោះព្រះអនាគាមិបុគ្គលនោះ អាចផុតស្រឡះចាកការកើតក្នុងមនុស្សភូមិ និងក្នុងទេវភូមិ តទៅក៏ទៅកើតតែក្នុងរូបភូមិ និងអរូបភូមិប៉ុណ្ណោះ ទាំងនេះព្រោះ ឧទ្ធម្ភាគិ-យសំយោជនៈនៅមាន ។

លុះកាលណាសម្រេចជាព្រះអរហន្ត ក៏អាចផុតស្រឡះពីឧបរិមសង្សារទៀត ។ លុះកាលណាបរិនិព្វាន នុ៎ះក៏គឺ ជាការ

ផុតស្រឡះចាកសេចក្ដីវិលវល់ស្លាប់កើតហើយ មិនថាក្នុងសំសារណាៗឡើយ ទាំងនេះព្រោះបានកាត់ផ្ដាច់នូវខ្សែនៃសំយោជនធម៌ ១០ ប្រការ ដាច់ធ្លាក់ចុះមិនមានសេសសល់នោះឯង ។

ម្យ៉ាងទៀត ក្នុងបរមត្ថទីបនីដីកាសម្ដែងថា **សំយោជនៈ** ដែលត្រូវប្រហារដោយមគ្គខាងក្រោមគឺ សោតាបត្តិមគ្គ សកទាគាមិមគ្គ និងអនាគាមិមគ្គ នេះឈ្មោះថា **ឱរម្ភាគិយសំយោជនៈ** ចំណែកសំយោជនៈដែលត្រូវប្រហារដោយអរហត្តមគ្គនោះ ឈ្មោះថា **ឧទ្ធម្ភាគិយសំយោជនៈ** ។

## ចំណែកសំយោជនៈ
## ១០ តាមន័យនៃព្រះអភិធម្ម

**១ - កាមរាគសំយោជនៈ** ធម្មជាតិដែលចងសត្វទុកដោយអាការដែលជាប់ជំពាក់នៅក្នុងកាមគុណអារម្មណ៍ អង្គធម៌បានដល់ លោភចេតសិកដែលប្រកបក្នុងលោភមូលចិត្ត ៨ ។

**២ - ភវរាគសំយោជនៈ** ធម្មជាតិដែលចងសត្វទុកដោយអាការដែលជាប់ជំពាក់នៅក្នុងរូបភព អរូបភព ឬ រូបឈាន អរូបឈាន អង្គធម៌បានដល់ លោភចេតសិកដែលប្រកបក្នុង

ទិដ្ឋិគតវិប្បយុត្តចិត្ត៤ ។

៣ - **បដិឃសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលក្រោធខឹង អង្គធម៌បានដល់ ទោសចេតសិក ដែលប្រកបក្នុងទោសមូលចិត្ត ២ ។

៤ - **មានសំយោជនៈ** ធម្មជាតិដែលចងសត្វទុកដោយ អាការដែលក្រអឺត លើកកម្ពស់ វាយឫក អង្គធម៌បានដល់ មានចេតសិកដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត៤ ។

៥ - **ទិដ្ឋិសំយោជនៈ** ធម្មជាតិដែលចងសត្វទុកដោយ អាការដែលយល់ឃើញខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិក ដែលប្រកបក្នុងទិដ្ឋិគតសម្បយុត្តចិត្ត៤ ។

៦ - **សីលព្វតបរាមាសសំយោជនៈ** ធម្មជាតិដែល ចងសត្វទុកដោយអាការដែលស្ទាបអង្អែលក្នុងវត្តប្រតិបត្តិខុស អង្គធម៌ បានដល់ ទិដ្ឋិចេតសិកដែលប្រកបក្នុងទិដ្ឋិគតសម្បយុត្ត ចិត្ត៤ ។

៧ - **វិចិកិច្ឆាសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលសង្ស័យ ស្ទាក់ស្ទើរចិត្តក្នុងវត្ថុដែលគួរជឿ

អន្តធម៌បានដល់ វិចិកិច្ឆាចេតសិក ដែលប្រកបក្នុងវិចិកិច្ឆា-សម្បយុត្តចិត្ត១ ។

**៨ - ឥស្សាសំយោជនៈ** ធម្មជាតិដែលចងសត្វទុកដោយអាការដែលច្រណែនក្នុងគុណគឺ សេចក្តីល្អរបស់អ្នកដទៃ អន្តធម៌បានដល់ ឥស្សាចេតសិកដែលប្រកបក្នុងទោសមូលចិត្ត២ ។

**៩ - មច្ឆរិយសំយោជនៈ** ធម្មជាតិដែលចងសត្វទុកដោយអាការដែលកំណាញ់ហួងហែងក្នុងសម្បត្តិ ឬគុណសេចក្តីល្អរបស់ខ្លួនឯង អន្តធម៌បានដល់ មច្ឆរិយចេតសិកដែលប្រកបក្នុងទោសមូលចិត្ត២ ។

**១០ - អវិជ្ជាសំយោជនៈ** ធម្មជាតិដែលចងសត្វទុកដោយអាការដែលវង្វេង ល្ងង់ខ្លៅ មិនដឹងសភាវធម៌តាមសេចក្តីពិត អន្តធម៌បានដល់ មោហចេតសិកដែលប្រកបក្នុងអកុសលចិត្ត១២ ។

## ឱរម្ភាគិយសំយោជនៈ ៧ ប្រការ

| | |
|---|---|
| ១ - កាមរាគសំយោជនៈ | ២ - បដិឃសំយោជនៈ |
| ៣ - ទិដ្ឋិសំយោជនៈ | ៤-សីលព្វតបរាមាសសំយោជនៈ |
| ៥ - វិចិកិច្ឆាសំយោជនៈ | ៦ - ឥស្សាសំយោជនៈ |

៧ - មច្ឆរិយសំយោជនៈ ។

## ឧទ្ធម្ភាគិយសំយោជនៈ ៣ ប្រការ

១ - ភវរាគសំយោជនៈ ២ - មានសំយោជនៈ

៣ - អវិជ្ជាសំយោជនៈ ។

សំយោជនៈ ១០ ប្រការ តាមន័យនៃព្រះអភិធម្មនេះ ឱរម្ភាគិយសំយោជនៈ គឺ កិលេសធម៌ដែលជាចំណែកចងសត្វទុកក្នុងភូមិខាងក្រោមមាន៧ប្រការ ប៉ុន្តែចំណែកឧទ្ធម្ភាគិយសំយោជនៈ គឺកិលេសដែលជាចំណែកចងសត្វទុកក្នុងភូមិខាងលើ នៅមានត្រឹមតែ ៣ ប្រការប៉ុណ្ណោះ ។

ចំណែកហេតុផលដែលចងសត្វទុក ក្នុងហេដ្ឋិមសង្សារវដ្ដ ក្នុងមជ្ឈិមសង្សារវដ្ដ ក្នុងឧបរិមសង្សារវដ្ដ រហូតដល់ការកាត់ផ្ដាច់សំយោជនៈ ដាច់ជាសមុច្ឆេទក្តី គប្បីជ្រាបអនុលោមតាមដែលបានពោលរួចមកហើយចុះ ។

## សង្គ្រោះអង្គធម៌របស់
## សំយោជនៈតាមន័យទាំង ២

សំយោជនៈតាមន័យនៃព្រះសូត្រ ១០ ប្រការ មានអង្គធម៌ ៧ គឺ :

១ - លោភចេតសិក ២ - ទោសចេតសិក

៣ - មានចេតសិក ៤ - ទិដ្ឋិចេតសិក

៥ - វិចិកិច្ឆាចេតសិក ៦ - ឧទ្ធច្ចចេតសិក

៧ - មោហចេតសិក ។

សំយោជនៈតាមន័យនៃព្រះអភិធម្ម ១០ ប្រការ មានអង្គធម៌ ៨ គឺ :-

១ - លោភចេតសិក ២ - ទោសចេតសិក

៣ - មានចេតសិក ៤ - ទិដ្ឋិចេតសិក

៥ - វិចិកិច្ឆាចេតសិក ៦ - ឥស្សាចេតសិក

៧ - មច្ឆរិយចេតសិក ៨ - មោហចេតសិក

កាលបើរួបរួមនូវអង្គធម៌របស់សំយោជនៈទាំង ២ ន័យនោះ ក៏បាននូវអង្គធម៌ ៩ គឺ :

១ - លោភចេតសិក ២ - ទោសចេតសិក

៣ - មានចេតសិក ៤ - ទិដ្ឋិចេតសិក

៥ - វិចិកិច្ឆាចេតសិក ៦ - ឥស្សាចេតសិក

៧ - មច្ឆរិយចេតសិក ៨ - ឧទ្ធច្ចចេតសិក

៩ - មោហចេតសិក ។

## ៩ - កិលេស

**កិលេស** គឺ ជាធម្មជាតិដែលជាគ្រឿងធ្វើឲ្យសៅហ្មងពេលពលទាំងចិត្តទាំងកាយ។ បានសេចក្ដីថា ចិត្ត ចេតសិក រូបដែលកើតព្រមជាមួយនឹងកិលេសទាំងឡាយ លុះកាលណា ប្រកបនឹងកិលេសទាំងឡាយ រមែងនឹងត្រូវសៅហ្មងពេលពល ទៅតាមកិលេសនោះៗដែរ ។ កិលេសទាំងឡាយកាលណា ប្រកបជាមួយនឹងចិត្តហើយ រមែងធ្វើឲ្យចិត្តទៅជាអកុសល តាមចេតសិកកិលេសនោះផង និង ធ្វើឲ្យរូបដែលកើតអំពី អកុសលចិត្តទាំងនោះ ទៅជាមានអាការសៅហ្មង ពេលពល ផង ។ ព្រោះតាមធម្មតា ចិត្ត និងកិរិយាអាការរបស់បុគ្គល ណាមួយបើមិនបានប្រកបនឹងកិលេស គឺ សេចក្ដីលោភ សេចក្ដី

ក្រោធ សេចក្ដីវង្វេងជាដើមហើយ បុគ្គលនោះនឹងដឹងខ្លួនថា ចិត្តខណៈនោះ ស្រស់ស្រាយ សប្បាយចិត្ត មុខមាត់ស្រស់បស់ មិនមានសេចក្ដីសុបសៅ ក្រហល់ក្រហាយកាយចិត្ត ដោយប្រការណាឡើយ ហើយក៏ជាទីសប្បាយភ្នែក សប្បាយចិត្តដល់អ្នកដទៃដែលបានមកជួបទៀត ។ ប៉ុន្តែបើក្នុងខណៈណាចិត្តរបស់បុគ្គលណាមួយមានសេចក្ដីលោភ សេចក្ដីក្រោធគ្របសង្កត់រួបរឹតហើយ បុគ្គលនោះក៏មានសេចក្ដីក្ដៅក្រហាយមួម៉ៅចិត្ត មុខមាត់ក៏មិនស្រស់បស់ ក្រៀមក្រំ ស្រពាប់ស្រពោនប្រាកដឡើង ថែមទាំងមិនជាទីសប្បាយភ្នែក សប្បាយចិត្តដល់អ្នកដែលបានមកជួបទៀតផង ។

ព្រោះហេតុនោះហើយ ព្រះពុទ្ធជាម្ចាស់ព្រះអង្គទើបទ្រង់ហៅអកុសលចេតសិកប្រការខ្លះ ដែលមានសភាពធ្វើឲ្យសៅហ្មងដល់កាយនិងចិត្តនេះថាជា កិលេស ដូចមានវចនត្ថថា :

**កិលេសេន្តិ ឧបតាបេន្តីតិ = កិលេសា**

ប្រែថា ធម្មជាតិណា រមែងធ្វើឲ្យរោលរាលសៅហ្មងធម្មជាតិនោះឈ្មោះថា **កិលេស** ។

ន័យម្យ៉ាងទៀត

**កិលិស្សតិ ឯតេហីតិ = កិលេសា**

ប្រែថា សម្បយុត្តធម៌ គឺ ចិត្ត ចេតសិក រមែងសៅហ្មង ពោលពាល ដោយធម្មជាតិណា ដូច្នោះ ធម្មជាតិដែលជាហេតុ នៃសេចក្ដីសៅហ្មង ពោលពាល របស់សម្បយុត្តធម៌នោះ ទើបឈ្មោះថា **កិលេស** ។

## កិលេសមាន ១០ ប្រការ

**១ - លោភកិលេស** ធម្មជាតិដែលជាគ្រឿងសៅហ្មង ពោលពាល ព្រោះសេចក្ដីត្រេកអរ ពេញចិត្តក្នុងលោកិយ-អារម្មណ៍ផ្សេងៗ អង្គធម៌បានដល់ លោភចេតសិកដែលប្រកប ក្នុងលោភមូលចិត្ត ៨ ។

**២ - ទោសកិលេស** ធម្មជាតិដែលជាគ្រឿងសៅហ្មង ពោលពាល ព្រោះសេចក្ដីក្រោធ សេចក្ដីមិនពេញចិត្ត អង្គធម៌ បានដល់ ទោសចេតសិក ដែលប្រកបក្នុងទោសមូលចិត្ត២ ។

**៣ - មោហកិលេស** ធម្មជាតិដែលជាគ្រឿងសៅហ្មង ពោលពាល ព្រោះសេចក្ដីវង្វេង លុង់ខ្លៅ មិនដឹងសភាវធម៌តាម

សេចក្ដីពិត អង្គធម៌បានដល់ មោហចេតសិកដែលប្រកបក្នុង អកុសលចិត្ត១២ ។

**៤ - មានកិលេស** ធម្មជាតិដែលជាគ្រឿងសៅហ្មង ពាលពាល ព្រោះការក្រអឺត លើកកម្ពស់ វាយឫក អង្គធម៌ បានដល់ មានចេតសិកដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត៤។

**៥ - ទិដ្ឋិកិលេស** ធម្មជាតិដែលជាគ្រឿងសៅហ្មង ពាលពាល ព្រោះសេចក្ដីយល់ឃើញខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិក ដែលប្រកបក្នុងទិដ្ឋិគតសម្បយុត្តចិត្ត៤ ។

**៦-វិចិកិច្ឆាកិលេស** ធម្មជាតិដែលជាគ្រឿងសៅហ្មង ពាលពាល ព្រោះសេចក្ដីសង្ស័យ ស្ទាក់ស្ទើរចិត្តក្នុងវត្ថុដែល គួរជឿ អង្គធម៌បានដល់ វិចិកិច្ឆាចេតសិក ដែលប្រកបក្នុង វិចិកិច្ឆាសម្បយុត្តចិត្ត១ ។

**៧-ថីនកិលេស** ធម្មជាតិដែលជាគ្រឿងសៅហ្មង ពាល-ពាល ព្រោះសេចក្ដីធោកធ្មុយ រួញរាចាកអារម្មណ៍ អង្គធម៌ បានដល់ ថីនចេតសិក ដែលប្រកបក្នុងអកុសលសសង្ខារិក-ចិត្ត៥ ។

**៨ - ឧទ្ធច្ចកិលេស** ធម្មជាតិដែលជាគ្រឿងសៅហ្មងពេលពល ព្រោះការពាយមាយ អណ្តែតអណ្តូង អង្គធម៌បានដល់ ឧទ្ធច្ចចេតសិក ដែលប្រកបក្នុងអកុសលចិត្ត ១២ ។

**៩ - អហិរិកកិលេស** ធម្មជាតិដែលជាគ្រឿងសៅហ្មងពេលពល ព្រោះសេចក្តីមិនខ្មាសមិនខ្ពើមចំពោះបាបទុច្ចរិត អង្គធម៌បានដល់ អហិរិកចេតសិក ដែលប្រកបក្នុងអកុសល-ចិត្ត១២ ។

**១០ - អនោត្តប្បកិលេស** ធម្មជាតិដែលជាគ្រឿងសៅហ្មងពេលពល ព្រោះសេចក្តីមិនខ្លាចក្រែង មិនស្ទុតចំពោះបាបទុច្ចរិត អង្គធម៌បានដល់ អនោត្តប្បចេតសិក ដែលប្រកបក្នុងអកុសលចិត្ត ១២ ។

ក្នុងកិលេស ១០ ប្រការនេះ បើពោលដោយអង្គធម៌មាន ១០ ប្រការ ស្មើគ្នា ។

## ធម៌ដែលលះបង់កិលេស ១០

- បញ្ញាក្នុងសោតាបត្តិមគ្គចិត្ត លះបង់ទិដ្ឋិកិលេសនិងវិចិកិច្ឆាកិលេស ។

- បញ្ញាក្នុងអនាគាមិមគ្គចិត្ត លះបង់ទោសកិលេស ។
- បញ្ញាក្នុងអរហត្តមគ្គចិត្ត លះបង់កិលេសដែលនៅសល់ ៧ ទៀតទាំងអស់ ។

## ស្ថានរបស់កិលេស

កិលេសទាំងឡាយ ចែកចេញបានជា ៣ ថ្នាក់គឺ :-

១ - **អនុស័យកិលេស** ជាកិលេសល្អិតដែលដេកជ្រកសំងំជាប្រចាំនៅក្នុងខន្ធសន្តាន គឺជាកិលេសដែលលះមិនទាន់បាន ។

២ - **បរិយុដ្ឋានកិលេស** ជាកិលេសថ្នាក់កណ្តាលដែលកើតប្រាកដតាមផ្លូវចិត្ត ។

៣ - **វីតិក្កមកិលេស** ជាកិលេសថ្នាក់គ្រោតគ្រាតដែលសម្តែងចេញទៅតាមផ្លូវកាយ និងផ្លូវវាចា ។

## កិលេសពិស្តារ ១៥០០

កិលេសធម៌ ១០ ប្រការនេះ កាលបើរាប់ទៅដោយសភាវៈរបស់អារម្មណ៍ ដែលជាបច្ច័យឲ្យកើតកិលេសបាន មានទាំងអស់ ១៥០០ ប្រការ គឺ :-

ធម៌ដែលជាអារម្មណ៍របស់កិលេស ដោយសភាវធម៌មាន ៧៥ បានដល់ :-

**ចិត្ត** ១ ( លោកិយចិត្ត៨១ រាប់យក ១ )

**ចេតសិក** ៥២

**និប្ផន្នរូប** ១៨

**លក្ខណរូប** ៤

អារម្មណ៍ទាំងនេះ រមែងមានទៅក្នុងខ្លួនជាអជ្ឈត្តារម្មណ៍ និងមានទៅក្នុងអ្នកដទៃ ដែលជាអារម្មណ៍ខាងក្រៅ ជាពហិទ្ធារម្មណ៍ បានទាំង ២ ប្រការ ។

អារម្មណ៍របស់កិលេសដែលជាអជ្ឈត្តធម៌ មាន ៧៥ ។

អារម្មណ៍របស់កិលេសដែលជាពហិទ្ធធម៌ មាន ៧៥ ។

ដូច្នោះអារម្មណធម៌របស់កិលេស ទាំងខាងក្នុង និងទាំងខាងក្រៅ ទាំងអស់មាន ១៥០ ប្រការ ។

កិលេសទាំងអស់ មាន ១០ ។

ដូច្នោះ អារម្មណ៍១៥០ x កិលេស១០ = កិលេស ១៥០០ ប្រការ ។

សរុបអារម្មណ៍ដែលជាបច្ច័យរបស់កិលេស ទាំងអជ្ឈត្ត-ធម៌និងពហិទ្ធធម៌ ទើបបានជាកិលេសពិស្ដារ ១៥០០ប្រការ ។

**រូបមន្ត**

សភាវធម៌ ៧៥ x អជ្ឈត្តពហិទ្ធ២ x កិលេស១០ = កិលេស ១៥០០ ។

## តណ្ហា ១០៨

ចំពោះ តណ្ហា ក៏មានការចែកចេញទៅដោយពិស្ដារដែរ មានតណ្ហា ១០៨ ប្រភេទ គឺ :-

ដោយអារម្មណ៍របស់តណ្ហាមាន ៦ គឺ រូបតណ្ហា សទ្ទ-តណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា និងធម្មតណ្ហា ។

ដោយសភាពរបស់តណ្ហាមាន ៣ បានដល់ កាមតណ្ហា១ ភវតណ្ហា១ និងវិភវតណ្ហា១ ។

តណ្ហាដោយអារម្មណ៍៦ ដោយសភាព ៣ ត្រូវជាតណ្ហា ១៨ ។

តណ្ហា ១៨ នេះ កើតឡើងនៅក្នុងសន្ដានរបស់ខ្លួន ជា អជ្ឈត្តៈ ១៨ និងកើតឡើងខាងក្រៅសន្ដានរបស់ខ្លួន គឺ អ្នក

ជទៃ ជាពហិទ្ធៈ ១៨ ទើបត្រូវជាតណ្ហា ៣៦ ប្រការ ។

ដោយកាល តណ្ហាទាំង ៣៦ ប្រការនេះ រមែងកើតបាន ក្នុងកាលទាំង ៣ ជាបច្ចុប្បន្ន១ អតីត១ និងអនាគត១ គឺ :-

៣ x ៣៦ = ១០៨ គឺ ត្រូវបានជាតណ្ហា ១០៨ប្រការ។

**រូបមន្ត**

អារម្មណ៍ ៦ x តណ្ហា៣ x អជ្ឈត្តពហិទ្ធ២ x កាល៣ = តណ្ហា ១០៨ ។

## សរុបអង្គធម៌ក្នុង
## អកុសលសង្គហៈ ៩ កង

លោភចេតសិក ជាអង្គធម៌របស់អកុសលទាំង ៩ កង ។

ទិដ្ឋិចេតសិក ជាអង្គធម៌របស់អកុសលទាំង៨កង ( វៀរនីវរណៈ ) ។

មោហចេតសិក ជាអង្គធម៌របស់អកុសលទាំង ៧ កង ( វៀរគន្ថៈ ឧបាទាន ) ។

ទោសចេតសិក ជាអង្គធម៌របស់អកុសលទាំង ៥ កង

គឺ គន្ថៈ នីវរណៈ អនុស័យ សំយោជនៈ កិលេស ។

វិចិកិច្ឆាចេតសិក ជាអង្គធម៌របស់អកុសលទាំង ៤ កង គឺ នីវរណៈ អនុស័យ សំយោជនៈ កិលេស ។

ឧទ្ធច្ចចេតសិក ជាអង្គធម៌របស់អកុសលធម៌ទាំង ៣ កង គឺ នីវរណៈ សំយោជនៈ កិលេស ។

មានចេតសិក ជាអង្គធម៌របស់អកុសលទាំង ៣ កង គឺ អនុស័យ សំយោជនៈ កិលេស ។

ថីនចេតសិក ជាអង្គធម៌របស់អកុសលទាំង ២ កង គឺ នីវរណៈ កិលេស ។

មិទ្ធចេតសិក ជាអង្គធម៌នៃអកុសល១កង គឺ នីវរណៈ។

កុក្កុច្ចចេតសិក ជាអង្គធម៌នៃអកុសល១កង គឺនីវរណៈ។

ឥស្សាចេតសិក ជាអង្គធម៌របស់អកុសល១កង គឺ សំយោជនៈ ។

មច្ឆរិយចេតសិក ជាអង្គធម៌របស់អកុសល១កង គឺ សំយោជនៈ ។

អហិរិកចេតសិក ជាអង្គធម៌នៃអកុសល១កង គឺ កិលេស ។

អនោត្តប្បចេតសិក ជាអង្គធម៌របស់អកុសល១កង គឺ កិលេស ។

**( ចប់អកុសលសង្គហៈ )**

## ពួក ទី២

# មិស្សកសង្គហៈ

មិស្សកសង្គហៈ ជាពួកដែលសង្គ្រោះសភាវធម៌ផ្សេង ៗ ដោយសភាពជាកុសល អកុសល និងអព្យាកតៈ ប្រឡូកចូលគ្នា ដូចហេតុសង្គហៈជាដើម ជាធម៌ដែលជាកុសលក៏មាន ជាអកុសលក៏មាន និងជាអព្យាកតៈក៏មាន ប្រឡូកប្រឡំគ្នា ដូចមានវចនត្ថថា :-

**កុសលាកុសលាព្យាកតា មិស្សកានំ**
**ហេតុឆក្កាទីនំ សង្គហោតិ = មិស្សកសង្គហោ**

ប្រែថា ពួកធម៌ផ្សេងៗ មានហេតុ៦ជាដើម ដែលសង្គ្រោះប្រឡូកប្រឡំចូលគ្នា ទាំងកុសល អកុសល និងអព្យាកតៈបាននោះ ហៅថា **មិស្សកសង្គហៈ** ។

មិស្សកសង្គហៈនេះ មានចំណែកការសម្តែងធម៌ចេញជា ៧ កង គឺ :-

១. ហេតុ , ២. ឈានង្គៈ , ៣. មគ្គង្គៈ , ៤. ឥន្ទ្រិយ

៥ . ពលៈ , ៦ . អធិបតី , ៧ . អាហារ ។

មានគាថាសង្គហៈដែលសម្ដែងទុកយ៉ាងនេះ គឺ :-

## គាថាសង្គហៈ ទី៤

ឆហេតូ បញ្ចឈានង្គា មគ្គង្គា នវ វត្ថុតោ
សោឡសិន្ទ្រិយធម្មា ច ពលធម្មា នវេរិតា ។

## គាថាសង្គហៈ ទី៥

ចត្តារោធិបតី វុត្តា តថាហារាតិ សត្តធា
កុសលាទិសមាកិណ្ណោ វុត្តោ មិស្សកសង្គហោ ។

គាថាសង្គហៈទី ៤ ប្រែថា ហេតុ មានអង្គធម៌បរមត្ថ ៦, ឈានង្គៈមានអង្គធម៌បរមត្ថ ៥ , មគ្គង្គៈ មានអង្គធម៌-បរមត្ថ ៩, ឥន្ទ្រិយ មានអង្គធម៌បរមត្ថ ១៦, ពលៈ មានអង្គធម៌បរមត្ថ ៩ ។

គាថាសង្គហៈទី៥ ប្រែថា អធិបតី មានអង្គធម៌បរមត្ថ៤ , អាហារក៏មានអង្គធម៌បរមត្ថ៤ ដូចគ្នា គប្បីជ្រាបការសម្ដែងមិស្សកសង្គហៈដែលមានកុសលជាដើម ច្រឡូកច្រឡំចូលគ្នា

ដោយមាន ៧ កង យ៉ាងនេះ ។

បើពោលដោយប្រភេទ មាន ៦៤ ប្រភេទ នឹងសម្ដែង តាមលំដាប់តទៅ :

## ១ - ហេតុ

ហេតុ គឺជាធម៌ដែលធ្វើឲ្យផលធម៌កើតឡើង ធ្វើឲ្យផលធម៌នោះតាំងមាំបានក្នុងអារម្មណ៍ និងធ្វើឲ្យចម្រើនឡើងបាន ដូចមានវចនត្ថសម្ដែងថា :-

**ហិនោតិ វត្តតិ ផលំ ឯតេហិ ឥតិ ហេតវោ**

**លទ្ធហេតូហិ តេ ចិភ រុឡ្ហមូលាវ បាទបា ។**

ប្រែថា ផលធម៌រមែងកើតឡើងព្រោះធម៌ទាំងនេះ ដូច្នេះ ធម៌ទាំងនេះ ទើបឈ្មោះថា **ហេតុ** ។

បានសេចក្ដីថា ធម៌ទាំងឡាយដែលបានឧបការអំពីហេតុ រមែងមានសភាពមាំមួនក្នុងអារម្មណ៍ ដូចជាដើមឈើដែលមានឫសចាក់ជ្រៅដូច្នោះ ។

## ហេតុមាន ៦ ប្រភេទ

**១-លោភហេតុ** ធម្មជាតិដែលជាសេចក្តីប្រាថ្នា ចំណង់ចង់បាន ជាហេតុឲ្យរូបនាមដែលកើតព្រមគ្នានឹងខ្លួន តាំងមាំនិងចម្រើនឡើងបានក្នុងអារម្មណ៍ អង្គធម៌បានដល់ លោភ-ចេតសិកដែលប្រកបក្នុងលោភមូលចិត្ត ៨ ។

**២-ទោសហេតុ** ធម្មជាតិដែលជាសេចក្តីក្រោធជាហេតុឲ្យរូបនាមដែលកើតព្រមគ្នានឹងខ្លួន តាំងមាំនិងចម្រើនឡើងបានក្នុងអារម្មណ៍ អង្គធម៌បានដល់ ទោសចេតសិកដែលប្រកបក្នុងទោសមូលចិត្ត ២ ។

**៣-មោហហេតុ** ធម្មជាតិដែលជាសេចក្តីល្ងង់ សេចក្តីវង្វេង ជាហេតុឲ្យរូបនាមដែលកើតព្រមគ្នានឹងខ្លួន តាំងមាំនិងចម្រើនឡើងបានក្នុងអារម្មណ៍ អង្គធម៌បានដល់មោហចេតសិកដែលប្រកបក្នុងអកុសលចិត្ត ១២ ។

**៤-អលោភហេតុ** ធម្មជាតិដែលជាសេចក្តីមិនជាប់ជំពាក់ចិត្តក្នុងកាមគុណអារម្មណ៍ គឺសេចក្តីមិនលោភ ឬការបរិច្ចាគជាហេតុឲ្យរូបនាមដែលកើតព្រមនឹងខ្លួន តាំងមាំ និង ចម្រើន

ឡើងបានក្នុងអារម្មណ៍ អន្តធម៌បានដល់ អលោភចេតសិក ដែលប្រកបក្នុងសោភណចិត្ត ៥៩ ឬ ៩១ ។

**៥-អទោសហេតុ** ធម្មជាតិដែលជាសេចក្តីមិនក្រោធ អំណត់អត់ធន់ និងមេត្តាអនុគ្រោះ ជាហេតុឲ្យរូបនាមដែលកើតព្រមគ្នានឹងខ្លួន តាំងមាំ និងចម្រើនឡើងបានក្នុងអារម្មណ៍ អន្តធម៌បានដល់ អទោសចេតសិក ដែលប្រកបក្នុងសោភណ-ចិត្ត ៥៩ ឬ ៩១ ។

**៦-អមោហហេតុ** ធម្មជាតិដែលជាសេចក្តីឈ្លាសឆ្លាត សេចក្តីមិនវង្វេងល្ងង់ខ្លៅ ជាហេតុឲ្យរូបនាមដែលកើតព្រមគ្នានឹងខ្លួន តាំងមាំ និងចម្រើនឡើងបានក្នុងអារម្មណ៍ អន្តធម៌បានដល់ បញ្ញាចេតសិកដែលប្រកបក្នុងញាណសម្បយុត្តចិត្ត ៤៧ ឬ ៧៩ ។

លោភហេតុ ទោសហេតុ មោហហេតុ ទាំង៣នេះ ជាហេតុដែលប្រកបក្នុងអកុសលចិត្តនិងអកុសលចេតសិក ទើបហៅថា **អកុសលហេតុ** ។

អលោភហេតុ អទោសហេតុ អមោហហេតុ ទាំង៣ នេះ

កាល ប្រកបនឹងសោភណចិត្តដែលជាកុសលហើយ ទើបហៅថា **កុសលហេតុ** ។

អលោភហេតុ អទោសហេតុ អមោហហេតុ ទាំង៣ នេះ កាល ប្រកបនឹងសោភណចិត្តដែលជាវិបាក និងកិរិយា ទើបហៅថា **អព្យាកតហេតុ** ។

ដោយអាស្រ័យហេតុទាំង ៦ ដូចដែលបានពោលមកនេះ មានទាំងអកុសលហេតុផង កុសលហេតុផង និងអព្យាកតហេតុផង ទើបនាំនូវធម៌ពួកនេះមកសម្តែងក្នុង មិស្សកសង្គហៈ ។

ចំពោះហេតុ ៦ ប្រការនេះ មានពោលពិស្តារហើយទុកក្នុងបរិច្ឆេទ ទី៣ ។

## ២ - ឈានង្គៈ

**ឈាន** ជាធម្មជាតិដែលធ្វើឲ្យចិត្តផ្តោត គឺ តាំងចិត្តសំដៅឆ្ពោះនឹងអារម្មណ៍ ឬជាការសម្លឹងអារម្មណ៍ គឺ ការស្ញឹងស្ញាចឹ មានវចនត្ថថា :

អាលម្ពមុបនិជ្ឈន្តិ ឥតិ ឈានានិ វុច្ចរេ
ឈាបេន្តិ វា បច្ចនិកេ ឥតិបិ ឈានសញ្ញិតា ។

ប្រែថា ធម៌ពួកណា រមែងសម្លឹងអារម្មណ៍ មានកសិណជាដើម ដូច្នោះធម៌ទាំងនោះឈ្មោះថា **ឈាន** ។

ធម៌ពួកណា រមែងដុតកម្តៅនូវធម៌ដែលជាបដិបក្ខនឹងខ្លួន ដូច្នោះធម៌ទាំងនោះឈ្មោះថា **ឈាន** បានដល់ អង្គឈាន៧ ។

ដូច្នោះដែលហៅថា **ឈាន** នោះ មាន ២ ន័យ គឺ :

**ឈាន** ជាធម្មជាតិដែលមានសភាពចូលទៅសម្លឹងនូវអារម្មណ៍យ៉ាងមាំ ។ ឯអារម្មណ៍ដែលត្រូវសម្លឹងនោះមិនបានកំណត់យកចំពោះតែ អារម្មណ៍ជាកម្មដ្ឋានប៉ុណ្ណោះទេ អារម្មណ៍អ្វីក៏ដោយ ទោះជាលោកិយ ឬលោកុត្តរក៏ដោយ ជាបរមត្ថ ឬបញ្ញត្តិក៏ដោយ ជាអារម្មណ៍របស់ឈានទាំងអស់ ។

ន័យម្យ៉ាងទៀត **ឈាន** ប្រែថា ដុត ពាក្យថា ដុតក្នុងទីនេះ សំដៅយកការធ្វើឲ្យធម៌ដែលជាបដិបក្ខនឹងខ្លួនមានកម្លាំងថយស្រុតចុះ ឬមិនឲ្យកើតឡើងបាន បានដល់ អង្គឈាន ៦ ដែលប្រកបក្នុងមហគ្គតចិត្ត ។

ចំណែកអង្គឈានដែលនៅក្នុងកាមចិត្តនោះ មានសភាព ចូលទៅសម្ងឹងអារម្មណ៍យ៉ាងមាំ ប្រាកដច្បាស់ជាងការដុតធម៌ ដែលជាបដិបក្ខនឹងខ្លួន ។

## ឈានង្គ: មាន ៧ ប្រការ

**១ - វិតក្ក** ធម្មជាតិដែលលើកចិត្តឡើងកាន់អារម្មណ៍ ជាគ្រឿងសម្ងឹងអារម្មណ៍ អង្គធម៌បានដល់វិតក្កចេតសិកដែល ប្រកបក្នុងកាមចិត្ត៤៤( វៀរទ្វិបញ្ចវិញ្ញាណ១០ ) បឋមជ្ឈាន ចិត្ត ១១ ។

**២ - វិចារ** ធម្មជាតិដែលពិចារណាគឺ ផ្គងចិត្តឲ្យជាប់ នៅក្នុងអារម្មណ៍ ជាគ្រឿងសម្ងឹងអារម្មណ៍ អង្គធម៌បានដល់ វិចារចេតសិកដែលប្រកបក្នុងកាមចិត្ត ៤៤ បឋមជ្ឈានចិត្ត១១ ទុតិយជ្ឈានចិត្ត ១១ ។

**៣ - បីតិ** ធម្មជាតិដែលមានសេចក្ដីរីករាយត្រេកអរ ក្នុងអារម្មណ៍ ញុំាងឲ្យឆ្អែតកាយ ឆ្អែតចិត្ត ជាគ្រឿងសម្ងឹង អារម្មណ៍អង្គធម៌បានដល់បីតិចេតសិក ដែលប្រកបក្នុងកាម-

សោមនស្សចិត្ត ១៨ , បឋមជ្ឈានចិត្ត១១ , ទុតិយជ្ឈានចិត្ត ១១ , និង តតិយជ្ឈានចិត្ត ១១ ។

**៤ - ឯកគ្គតា** ធម្មជាតិដែលតាំងនៅស៊ប់ក្នុងអារម្មណ៍តែមួយ យ៉ាងជាក់ច្បាស់ ជាគ្រឿងសម្លឹងអារម្មណ៍ អង្គធម៌បានដល់ ឯកគ្គតាចេតសិក ដែលប្រកបក្នុងចិត្ត ៧៩ ឬ១១១ ( វៀរទ្វិបញ្ចវិញ្ញាណ១០ ) ។

**៥- សោមនស្សវេទនា** ធម្មជាតិដែលសោយអារម្មណ៍ជាសុខនៃចិត្ត ជាគ្រឿងសម្លឹងអារម្មណ៍ អង្គធម៌បានដល់ វេទនាចេតសិក ដែលប្រកបក្នុងសោមនស្សសហគតចិត្ត៦២ ។

**៦ - ទោមនស្សវេទនា** ធម្មជាតិដែលសោយអារម្មណ៍ជាទុក្ខនៃចិត្ត ជាគ្រឿងសម្លឹងអារម្មណ៍ អង្គធម៌បានដល់ វេទនាចេតសិក ដែលប្រកបក្នុងទោសមូលចិត្ត ២ ។

**៧ - ឧបេក្ខាវេទនា** ធម្មជាតិដែលសោយអារម្មណ៍ជាកណ្តាល មិនសុខមិនទុក្ខ ជាគ្រឿងសម្លឹងអារម្មណ៍ អង្គធម៌បានដល់ វេទនាចេតសិក ដែលប្រកបក្នុងឧបេក្ខាសហគតចិត្ត ៤៧ ( វៀរឧបេក្ខាវេទនាក្នុងទ្វិបញ្ចវិញ្ញាណចិត្ត៨ ) ។

ឈានង្គៈមាន ៧ប្រភេទ ប៉ុន្តែអង្គធម៌មាន ៥ប្រការ គឺ វិតក្ក វិចារ បីតិ វេទនា និងឯកគ្គតា ។

ចំពោះ **សោមនស្ស ទោមនស្ស ឧបេក្ខា** ទាំង ៣ ប្រភេទ របស់ឈាននេះ មានអង្គធម៌គឺ វេទនាចេតសិកតែមួយគត់ ។

រួមសេចក្តីមក ធម៌ដែលជាអ្នកសម្លឹងអារម្មណ៍នោះ បានដល់ ឈាន៧ប្រភេទ នេះឯង ហើយចំពោះការសម្លឹងអារម្មណ៍ ក៏មានទាំងកុសល អកុសល និងអព្យាកត:បានទាំងអស់( វៀរតែទោមនស្សវេទនា មួយប្រភេទប៉ុណ្ណោះ ដែលបានចំពោះតែអកុសលប៉ុណ្ណោះ ) ដូច្នោះ ទើបចាត់ទូវឈានង្គៈទុកក្នុងពួកធម៌ដែលជា **មិស្សកសង្គហៈ** ។

ចំពោះឈានដែលដុតបដិបក្ខធម៌នឹងខ្លួននោះគឺ បានដល់តែឈាន ៦ ប្រភេទ( វៀរទោមនស្សវេទនា ) ដែលនៅក្នុងមហគ្គតចិត្តប៉ុណ្ណោះ ហើយរមែងដុតបដិបក្ខធម៌ បានយ៉ាងប្រាកដជាក់ច្បាស់ជាងឈានដែលនៅក្នុងកាមចិត្ត ។

ឈានដែលដុតបដិបក្ខធម៌ គឺ :

**វិតក្ក** ដុតបដិបក្ខធម៌ គឺ ថីនមិទ្ធ ។

**វិចារ** ជុតបដិបក្ខធម៌ គឺ វិចិកិច្ឆា ។

**បីតិ** ជុតបដិបក្ខធម៌ គឺ ព្យាបាទ ។

**សោមនស្ស** និង **ឧបេក្ខា** ជុតបដិបក្ខធម៌ គឺ ឧទ្ធច្ចកុក្កុច្ច ទោមនស្ស ។

**ឯកគ្គតា** ជុតបដិបក្ខធម៌ គឺ កាមច្ឆន្ទៈ ។

**សង្កេត :**

**ឯកគ្គតាចេតសិក** ដែលប្រកបក្នុងទ្វិបញ្ចវិញ្ញាណ ១០ មិនអាចជាឈានង្គៈបានទេ ។

**ទោមនស្ស** ជាគ្រឿងជុត ជាចំណែកអកុសល ក្នុងទីនេះ ដើម្បីឲ្យឃើញថា ទោមនស្សជាគូគ្នានឹងសោមនស្ស និងសំដៅយកទោមនស្សដែលកើតដល់ព្រះយោគាវចរដែលវិនាសចាកឈាន ។

## ៣ - មគ្គង្គៈ

**មគ្គ** ប្រែថា ផ្លូវ គឺ ធម្មជាតិដែលជាគ្រឿងនាំទៅកាន់គោលដៅ ដែលបានដល់ទុគ្គតិភូមិ សុគតិភូមិ និងនិព្វាន ដូច

មានវចនត្ថសម្តែងថា :

**សុគត្យា ច ទុគ្គត្យា ច   និព្វានស្ស ច បាបណា**
**តេសញ្ច   បថភូតតា   មគ្គង្គានីតិ   វុច្ចរេ**
**មគ្គស្ស   វា   អង្គានីតិ   មគ្គង្គានីតិ   សម្មតា ។**

ប្រែថា ធម៌ដែលជាហេតុឲ្យដល់ ទុគ្គតិភូមិ សុគតិភូមិ និព្វាន និងជាគន្លងផ្លូវឲ្យទៅកាន់ទុគ្គតិភូមិ សុគតិភូមិ និងព្រះនិព្វាន ឬន័យម្យ៉ាងទៀត ព្រោះជាធម៌ក្នុងចំណែកមួយរបស់មគ្គ ទើបហៅថា **អង្គមគ្គ** ។

ធម្មតាសត្វទាំងឡាយ ដែលអន្ទោលត្រាច់រង្គាត់ស្លាប់កើតនៅក្នុងភូមិផ្សេងៗ ទាំង ៣១ ភូមិក៏ដោយ ឬបុគ្គលអ្នកដែលបានចូលដល់ព្រះនិព្វានក៏ដោយ រមែងត្រូវអាស្រ័យហេតុនិងផ្លូវជួយបញ្ជូនឲ្យដល់ ។ ឯធម៌ដែលជាហេតុនិងជាផ្លូវឲ្យទៅដល់ភូមិផ្សេងៗ ឬដល់ព្រះនិព្វាននោះ បានដល់អង្គមគ្គ១២ប្រការ ។

## មគ្គង្គៈ មាន ១២ ប្រភេទ

**១ - សម្មាទិដ្ឋិ** សេចក្តីឃើញត្រូវ ជាផ្លូវឲ្យទៅដល់សុគតិភូមិនិងព្រះនិព្វាន អង្គធម៌បានដល់ បញ្ញាចេតសិកដែល

ប្រកបក្នុងញាណសម្បយុត្តចិត្ត ៤៧ ឬ ៧៩ ។

**២-សម្មាសង្កប្បៈ** សេចក្តីត្រិះរិះត្រូវ ជាផ្លូវឲ្យទៅដល់សុគតិភូមិនិងព្រះនិព្វាន អង្គធម៌បានដល់ វិតក្កចេតសិកដែលប្រកបក្នុងកាមាវចរសោភណចិត្ត២៤ និងបឋមជ្ឈានចិត្ត១១ ។

**៣ - សម្មាវាចា** ការពោលវាចាត្រូវ ជាផ្លូវឲ្យទៅដល់សុគតិភូមិ និងព្រះនិព្វាន អង្គធម៌បានដល់ សម្មាវាចាចេតសិកដែលប្រកបក្នុងមហាកុសលចិត្ត៨ និងលោកុត្តរចិត្ត៨ ឬ៤០។

**៤ - សម្មាកម្មន្តៈ** ការធ្វើការងារត្រូវ ជាផ្លូវឲ្យទៅដល់សុគតិភូមិនិងព្រះនិព្វាន អង្គធម៌បានដល់ សម្មាកម្មន្តចេតសិកដែលប្រកបក្នុងមហាកុសលចិត្ត៨ និងលោកុត្តរចិត្ត៨ ឬ ៤០ ។

**៥-សម្មាអាជីវៈ** ការចិញ្ចឹមជីវិតត្រូវ ជាផ្លូវឲ្យទៅដល់សុគតិភូមិនិងព្រះនិព្វាន អង្គធម៌បានដល់ សម្មាអាជីវចេតសិកដែលប្រកបក្នុងមហាកុសលចិត្ត៨និងលោកុត្តរចិត្ត៨ ឬ ៤០ ។

**៦ - សម្មាវាយាមៈ** សេចក្តីព្យាយាមត្រូវ ជាផ្លូវឲ្យទៅដល់សុគតិភូមិ និងព្រះនិព្វាន អង្គធម៌បានដល់ វីរិយចេតសិកដែលប្រកបក្នុងសោភណចិត្ត៥៩ ឬ ៩១ ។

៧ - **សម្មាសតិ** សេចក្ដីរលឹកត្រូវ ជាផ្លូវឲ្យទៅដល់សុគតិ និងព្រះនិព្វាន អង្គធម៌បានដល់ សតិចេតសិកដែលប្រកបក្នុងសោភណចិត្ត៥៩ ឬ ៩១ ។

៨ - **សម្មាសមាធិ** សេចក្ដីតម្កល់ចិត្តនឹងត្រូវ ជាផ្លូវឲ្យទៅដល់សុគតិភូមិ និងព្រះនិព្វាន អង្គធម៌បានដល់ ឯកគ្គតា-ចេតសិកដែលប្រកបក្នុងសោភណចិត្ត៥៩ ឬ ៩១ ។

៩ - **មិច្ឆាទិដ្ឋិ** សេចក្ដីឃើញខុស ជាផ្លូវឲ្យទៅដល់ទុគ្គតិភូមិ អង្គធម៌បានដល់ ទិដ្ឋិចេតសិកដែលប្រកបក្នុងទិដ្ឋិគតសម្បយុត្តចិត្ត៤ ។

១០ - **មិច្ឆាសង្កប្បៈ** សេចក្ដីត្រិះរិះខុស ជាផ្លូវឲ្យទៅដល់ទុគ្គតិភូមិ អង្គធម៌បានដល់ វិតក្កចេតសិកដែលប្រកបក្នុងអកុសលចិត្ត ១២ ។

១១ - **មិច្ឆាវាយាមៈ** សេចក្ដីព្យាយាមខុស ជាផ្លូវឲ្យទៅដល់ទុគ្គតិភូមិ អង្គធម៌បានដល់ វីរិយចេតសិកដែលប្រកបក្នុងអកុសលចិត្ត១២ ។

១២ - **មិច្ឆាសមាធិ** សេចក្ដីតម្កល់ចិត្តនឹងខុស ជាផ្លូវ

ឲ្យទៅដល់ទុគ្គតិភូមិ អង្គធម៌បានដល់ ឯកគ្គតាចេតសិកដែលប្រកបក្នុងអកុសលចិត្ត១១ ( វៀរវិចិកិច្ឆាសម្បយុត្តចិត្ត១ )។

ក្នុងចំនួនមគ្គង្គៈ ទាំង ១២ ប្រភេទនេះ មគ្គង្គៈដែលជាហេតុ និងជាគន្លងផ្លូវឲ្យចូលទៅដល់សុគតិភូមិ និងព្រះនិព្វានមាន ៨ ប្រការ គឺ :

សម្មាទិដ្ឋិ, សម្មាសង្កប្បៈ , សម្មាវាចា , សម្មាកម្មន្តៈ សម្មាអាជីវៈ , សម្មាវាយាមៈ , សម្មាសតិ , សម្មាសមាធិ។

ចំណែកមគ្គង្គៈដែលជាហេតុ និងជាគន្លងផ្លូវចូលទៅដល់ទុគ្គតិភូមិ មាន ៤ ប្រការ គឺ :

មិច្ឆាទិដ្ឋិ, មិច្ឆាសង្កប្បៈ, មិច្ឆាវាយាមៈ, មិច្ឆាសមាធិ។

នៅក្នុងព្រះសូត្រ ព្រះពុទ្ធអង្គទ្រង់សម្តែង អង្គនៃមគ្គមាន១៦ ប្រការ ដែលនៅមានអង្គនៃមគ្គដទៃ ៤ ប្រភេទទៀតផ្សេងពីអង្គនៃមគ្គ១២ប្រការ ខាងលើដែលបានពោលមកហើយ គឺ មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាសតិ ប៉ុន្តែកាលបើ ពោលដោយអង្គធម៌បរមត្ថ មិនមានដោយចំពោះទេ បានត្រឹមតែសង្គ្រោះចូលក្នុងអកុសលចិត្តុប្បាទដែលប្រព្រឹត្តទៅ

ដោយ វចីទុច្ចរិត កាយទុច្ចរិត ការចិញ្ចឹមជីវិតខុស និង ការរលឹកចំពោះក្នុងវត្ថុដែលជាទីតាំងនៃកំហុស ឬបើមិនដូច្នោះទេ **មិច្ឆាសតិ** សំដៅយកការរលឹក ចំពោះអារម្មណ៍ដទៃដែលក្រៅចាកសតិប្បដ្ឋាន ពោលគឺ មិនមែនជាអារម្មណ៍នៃកាយ វេទនា ចិត្ត ធម៌ ។

ចំពោះមគ្គង្គៈ ១២ ប្រការនេះ សំដៅយកតែសភាវធម៌ ឬអង្គធម៌ដោយត្រង់ប៉ុណ្ណោះ ទាំងសម្មាមគ្គ និងទាំងមិច្ឆាមគ្គ ដូច្នោះទើបចាត់ប្រភេទរបស់មគ្គង្គៈទុក ១២ ប្រការ ។

មគ្គង្គៈ ១២ ប្រការនេះ មានអង្គធម៌ត្រឹមតែ៩ ប៉ុណ្ណោះ គឺ បញ្ញាចេតសិក វិតក្កចេតសិក សម្មាវាចាចេតសិក សម្មា-កម្មន្តចេតសិក សម្មាអាជីវចេតសិក វីរិយចេតសិក សតិ-ចេតសិក ឯកគ្គតាចេតសិក និងទិដ្ឋិចេតសិក ។

នៅក្នុងអង្គធម៌ទាំង ៩ នេះ :-

**ទិដ្ឋិចេតសិក** ជាអកុសលតែម្យ៉ាង ។

**បញ្ញា សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ និង សតិចេតសិក** ប្រព្រឹត្តទៅបានទាំងកុសល និងទាំងអព្យាកតៈ ។

**វិតក្ក វីរិយ** និង **ឯកគ្គតាចេតសិក** ប្រព្រឹត្តទៅបានទាំង អកុសល ទាំងកុសល និងទាំងអព្យាកតៈ ។

ព្រោះហេតុនោះ មគ្គង្គៈ ទើបចាត់ទុកក្នុងពួកធម៌ដែល ជាមិស្សកសង្គហៈ ។

**សង្កេត :**

ចំពោះអហេតុកចិត្ត ១៨ និង ឯកគ្គតាចេតសិក ក្នុង វិចិកិច្ឆាសម្បយុត្តចិត្ត រមែងមិនមានអង្គនៃមគ្គ និងមិនមែន ជាអង្គនៃមគ្គក្នុងមគ្គង្គៈឡើយ ។

សេចក្តីទាំងនេះក៏ព្រោះតែអហេតុកចិត្ត ១៨ មិនមាន សម្បយុត្តហេតុណាសោះ ។ កាលបើមិនមានហេតុប្រកប ហើយ ក៏មិនមែនជាហេតុ ជាគន្លងផ្លូវ ឲ្យចូលទៅកាន់ទុគ្គតិ សុគតិ និង ព្រះនិព្វានបានទេ ។

ចំណែក **ឯកគ្គតាចេតសិក** ដែលប្រកបក្នុងវិចិកិច្ឆា-សម្បយុត្តចិត្ត ដែលមិនរាប់ថាជាអង្គមគ្គ ក៏ព្រោះហេតុថា វិចិកិច្ឆាសម្បយុត្តចិត្តនោះ សូម្បីមានមោហហេតុ ប្រកបពិត មែន ប៉ុន្តែមានកម្លាំងខ្សោយ ព្រោះមានត្រឹមតែមួយប៉ុណ្ណោះ

ហើយថែមទាំងមានសេចក្ដីស្ទាក់ស្ទើរចិត្តប្រកបទៀត ធ្វើឲ្យកម្លាំងដែលមាននៅមិនច្រើននោះ ក៏ត្រូវថយចុះទៀត ព្រោះមានអារម្មណ៍ប៉ាចហាច ទើបមិនដល់សភាពជាសមាធិក្នុងអង្គមគ្គ ។

ចំពោះអង្គមគ្គដែលកើតជាមួយនឹងវិបាក និងកិរិយាធ្វើនាទីនាំចិត្ត-ចេតសិកឲ្យទៅកាន់អារម្មណ៍ និង ឲ្យធ្វើកិច្ចទៅតាមនាទីរបស់ខ្លួនរៀងៗខ្លួន ។

## ៤ - ឥន្ទ្រិយ

**ឥន្ទ្រិយ** សំដៅយកភាពជាធំ ភាពជាអ្នកគ្រប់គ្រងដែលមានសមត្ថភាពធ្វើឲ្យសភាវធម៌ដែលកើតឡើងព្រមនឹងខ្លួននោះត្រូវប្រព្រឹត្តទៅតាមអំណាចគ្រប់គ្រងរបស់ខ្លួន ដូចមានវចនត្ថសម្ដែងថា :

**ឥន្ទន្តិ បរមឥស្សរិយំ ករោន្តីតិ = ឥន្ទ្រិយានិ**

ប្រែថា ធម៌ទាំងឡាយណាជាអ្នកគ្រប់គ្រង រមែងធ្វើខ្លួនឲ្យជាឥស្សរៈក្រៃលែង ធម៌ទាំងនោះ ឈ្មោះថា **ឥន្ទ្រិយ** ។

ភាពជាអ្នកគ្រប់គ្រងរបស់សភាវៈ ដែលជាឥន្ទ្រិយនោះរមែងជាអ្នកគ្រប់គ្រងចំពោះធម៌ ដែលកើតរួមនឹងខ្លួន និង ធ្វើ

កិច្ចការងារតាមមុខនាទីរបស់ខ្លួនប៉ុណ្ណោះ ។ បានសេចក្តីថា ធម៌ដែលកើតព្រមគ្នានោះ អាចមានមុខនាទីការងារដែលត្រូវធ្វើច្រើនយ៉ាង ប៉ុន្តែភាពជាអ្នកគ្រប់គ្រងនោះ រមែងគ្រប់គ្រងបានចំពោះតែការងារតាមមុខនាទីរបស់ខ្លួនប៉ុណ្ណោះ មិនទៅឈ្លានពានក្នុងមុខនាទីការងាររបស់អ្នកដទៃទេ ។ ដូច្នោះក្នុងកិច្ចការងារមួយមានមុខនាទីការងារដែលនឹងត្រូវធ្វើ មានច្រើនមុខ ទើបត្រូវមានធម៌ជាឥន្រ្ទិយច្រើនប្រការ ។

ក្នុងការឃើញ ការឮ ការធុំក្លិន ការដឹងរស ការដឹងផោដ្ឋព្វៈជាដើម ទាំងអស់នេះ រមែងមានធម៌ជាឥន្រ្ទិយនៅច្រើនប្រការ ដូចជាក្នុងការឃើញ ចក្ខុបសាទរូបជាឥន្រ្ទិយហៅថា **ចក្ខុន្រ្ទិយ** ព្រោះជាអ្នកគ្រប់គ្រងក្នុងការទទួលនូវរូបារម្មណ៍ បើមិនមានចក្ខុបសាទរូបទេ រូបដទៃៗនឹងមិនអាចទទួលរូបារម្មណ៍បានឡើយ ក្រៅពីចក្ខុន្រ្ទិយហើយនោះ ។

រូបជីវិតិន្រ្ទិយ ជាអ្នកគ្រប់គ្រងក្នុងការរក្សាកម្មជរូប រួមទាំងចក្ខុបសាទរូបដែលកើតព្រមនឹងខ្លួនផងដែរ ហើយមនិន្រ្ទិយ គឺ ចក្ខុវិញ្ញាណជាអ្នកគ្រប់គ្រងក្នុងការឃើញរូបារម្មណ៍ យ៉ាង

នេះជាដើម ។

ការឃើញបានជិតក្តី បានឆ្ងាយក្តី ឃើញបានច្បាស់ក្តី មិនបានច្បាស់ក្តី ក៏ព្រោះអាស្រ័យអំណាចនៃចក្ខុបសាទនោះឯង បើចក្ខុបសាទមានកម្លាំងខ្លាំង ការឃើញនោះក៏ឃើញបានឆ្ងាយ និងបានច្បាស់ និងបើចក្ខុបសាទមានកម្លាំងខ្សោយ ការឃើញនោះក៏ឃើញមិនបានឆ្ងាយ និង មិនបានច្បាស់ ។

ក្នុងការឮ ការធុំក្លិន ដឹងរស ដឹងផោដ្ឋព្វៈ នឹកគិតធម្មារម្មណ៍ ក៏ដូចគ្នាយ៉ាងនេះដែរ រមែងមានឥន្ទ្រិយដទៃៗកើតព្រមគ្នាបានច្រើនឥន្ទ្រិយ ហើយគ្រប់ៗឥន្ទ្រិយ ក៏មានមុខនាទីគ្រប់គ្រង គឺ ធ្វើសការធម៌ដែលទាក់ទិនគ្នានឹងខ្លួននោះ ឲ្យប្រព្រឹត្តទៅតាមអំណាចរបស់ខ្លួនដែរ ។

## ឥន្ទ្រិយមាន ២២ ប្រភេទ

**១ - ចក្ខុន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការឃើញអន្តធម៌បានដល់ **ចក្ខុបសាទ** ។

**២ - សោតិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការឮ អន្តធម៌បានដល់ **សោតបសាទ** ។

៣ - **ឃានិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការដឹងក្លិន អង្គធម៌បានដល់ **ឃានបសាទ** ។

៤ - **ជីវ្ហិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការដឹងរស អង្គធម៌បានដល់ **ជីវ្ហាបសាទ** ។

៥ - **កាយិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការដឹងផោដ្ឋព្វៈ អង្គធម៌បានដល់ **កាយបសាទ** ។

៦ - **ឥត្ថិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងភាពជានារី អង្គធម៌បានដល់ **ឥត្ថីភាវរូប** ។

៧ - **បុរិសិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងភាពជាបុរស អង្គធម៌បានដល់ **បុរិសភាវរូប** ។

៨ - **ជីវិតិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការរក្សាចិញ្ចឹមនាមរូប អង្គធម៌បានដល់ **ជីវិតិន្ទ្រិយចេតសិកនិងជីវិតរូប** ។

៩ - **មនិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការដឹងអារម្មណ៍ អង្គធម៌បានដល់ **ចិត្តទាំងអស់** ។

១០ - **សុខិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការ

សោយអារម្មណ៍ដែលសប្បាយកាយ អង្គធម៌បានដល់ **វេទនា-ចេតសិក** ដែលប្រកបក្នុងសុខសហគតកាយវិញ្ញាណចិត្ត ១ ។

**១១ - ទុក្ខិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការសោយអារម្មណ៍ដែលមិនសប្បាយកាយ អង្គធម៌បានដល់ **វេទ-នាចេតសិក** ដែលប្រកបក្នុងទុក្ខសហគតកាយវិញ្ញាណចិត្ត១ ។

**១២ - សោមនស្សិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការសោយអារម្មណ៍ដែលសប្បាយចិត្ត អង្គធម៌បានដល់ **វេទនាចេតសិក** ដែលប្រកបក្នុងសោមនស្សសហគតចិត្ត៦២ ។

**១៣ - ទោមនស្សិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការសោយអារម្មណ៍ដែលមិនសប្បាយចិត្ត អង្គធម៌បានដល់ **វេទនាចេតសិក** ដែលប្រកបក្នុងទោសមូលចិត្ត២ ។

**១៤ - ឧបេក្ខិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការសោយអារម្មណ៍ដែលជាកណ្តាល ព្រងើយៗ អង្គធម៌បានដល់ **វេទនាចេតសិក** ដែលប្រកបក្នុងឧបេក្ខាសហគតចិត្ត៥៥ ។

**១៥ - សទ្ធិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការជឿចំពោះវត្ថុដែលគួរជឿ អង្គធម៌បានដល់ **សទ្ធាចេតសិក**

ដែលប្រកបក្នុងលោកណាចិត្ត ៩១ ។

**១៦ - វីរិយិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការព្យាយាម អង្គធម៌បានដល់ **វីរិយចេតសិក** ដែលប្រកបក្នុងវីរិយសម្បយុត្តចិត្ត ១០៥ ។

**១៧ - សតិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការរលឹកត្រូវ អង្គធម៌បានដល់ **សតិចេតសិក** ដែលប្រកបក្នុងសោភណចិត្ត ៩១ ។

**១៨ - សមាធិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការតាំងចិត្តមាំក្នុងអារម្មណ៍ អង្គធម៌បានដល់ **ឯកគ្គតាចេតសិក** ដែលប្រកបក្នុងចិត្ត៧២(វៀរអវីរិយចិត្ត១៦ វិចិកិច្ឆាសម្បយុត្តចិត្ត១)។

**១៩ - បញ្ញិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការដឹងនូវសភាវធម៌តាមសេចក្ដីពិត អង្គធម៌បានដល់ **បញ្ញា-ចេតសិក** ដែលប្រកបក្នុងញាណសម្បយុត្តចិត្ត ៤៧ ឬ៧៩ ។

**២០ - អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការដឹងច្បាស់នូវអរិយសច្ចៈ៤ ដែលខ្លួនមិនធ្លាប់ដឹង អង្គធម៌បានដល់ **បញ្ញាចេតសិក** ប្រកបក្នុងសោតាបត្តិមគ្គចិត្ត១ ។

**២១ - អញ្ញិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការដឹងច្បាស់នូវអរិយសច្ចៈ ៤ ដែលខ្លួនធ្លាប់បានដឹងហើយ អង្គធម៌បានដល់ **បញ្ញាចេតសិក** ដែលប្រកបក្នុងសោតាបត្តិ-ផលចិត្ត ១ សកទាគាមិមគ្គចិត្ត ១ សកទាគាមិផលចិត្ត ១ អនាគាមិមគ្គចិត្ត១ អនាគាមិផលចិត្ត១ និងអរហត្តមគ្គចិត្ត១ ។

**២២ - អញ្ញាតាវិន្ទ្រិយ** ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការដឹងច្បាស់នូវអរិយសច្ចៈ៤ ជាទីបំផុត អង្គធម៌បានដល់ **បញ្ញាចេតសិក** ដែលប្រកបក្នុងអរហត្តផលចិត្ត១ ។

ឥន្ទ្រិយទាំង ២២ ប្រភេទនេះ មានអង្គធម៌ត្រឹមតែ ១៦ ប្រការប៉ុណ្ណោះគឺ ចក្ខុបសាទ , សោតបសាទ , ឃានបសាទ , ជីវ្ហាបសាទ , កាយបសាទ , ឥត្ថីភាវរូប បុរិសភាវរូប , ជីវិតរូប , ជីវិតិន្ទ្រិយចេតសិក , ចិត្ត , វេទនាចេតសិក , សទ្ធាចេតសិក , វីរិយចេតសិក , សតិចេតសិក , ឯកគ្គតា-ចេតសិក , បញ្ញាចេតសិក ។

## ការចែកឥន្ទ្រិយ ២២
## ដោយរូបធម៌ និងនាមធម៌

**ឥន្ទ្រិយ៧** គឺ ចក្ខុន្ទ្រិយ , សោតិន្ទ្រិយ , ឃានិន្ទ្រិយ , ជីវ្ហិន្ទ្រិយ , កាយិន្ទ្រិយ , ឥត្ថិន្ទ្រិយ , និង បុរិសិន្ទ្រិយ ជារូបធម៌ ។

**ឥន្ទ្រិយ ១៤** គឺ មនិន្ទ្រិយ , សុខិន្ទ្រិយ , ទុក្ខិន្ទ្រិយ , សោមនស្សិន្ទ្រិយ , ទោមនស្សិន្ទ្រិយ , ឧបេក្ខិន្ទ្រិយ , សទ្ធិន្ទ្រិយ , វីរិយិន្ទ្រិយ , សតិន្ទ្រិយ, សមាធិន្ទ្រិយ , បញ្ញិន្ទ្រិយ , អនញ្ញតញ្ញស្សាមីតិន្ទ្រិយ , អញ្ញិន្ទ្រិយ និង អញ្ញាតាវិន្ទ្រិយ ជានាមធម៌ ។

**ឥន្ទ្រិយ ១** គឺ ជីវិតិន្ទ្រិយ ជារូបផង ជានាមផង ។

## ការចែកឥន្ទ្រិយ ២២
## ជាលោកិយ និងលោកុត្តរ

**ឥន្ទ្រិយ១០** គឺ ចក្ខុន្ទ្រិយ , សោតិន្ទ្រិយ , ឃានិន្ទ្រិយ , ជីវ្ហិន្ទ្រិយ , កាយិន្ទ្រិយ , ឥត្ថិន្ទ្រិយ និង បុរិសិន្ទ្រិយ ,

សុខិន្ទ្រិយ , ទុក្ខិន្ទ្រិយ និង ទោមនស្សិន្ទ្រិយ ជាលោកិយ ។

**ឥន្ទ្រិយ ៣** គឺ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ , អញ្ញិន្ទ្រិយ , និងអញ្ញាតាវិន្ទ្រិយ ជាលោកុត្តរ ។

**ឥន្ទ្រិយ៩** គឺ ជីវិតិន្ទ្រិយ , មនិន្ទ្រិយ , សោមនស្សិន្ទ្រិយ, ឧបេក្ខិន្ទ្រិយ, សទ្ធិន្ទ្រិយ, វីរិយិន្ទ្រិយ, សតិន្ទ្រិយ សមាធិន្ទ្រិយនិងបញ្ញិន្ទ្រិយ ជាលោកិយផង លោកុត្តរផង ។

## ការបែកឥន្ទ្រិយ ២២
## ដោយហេតុ និង នហេតុ

**ឥន្ទ្រិយ ៤** គឺ បញ្ញិន្ទ្រិយ , អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ , អញ្ញិន្ទ្រិយ , អញ្ញាតាវិន្ទ្រិយ ជាហេតុ ។

**ឥន្ទ្រិយ១៨** គឺ ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ, ឃានិន្ទ្រិយ , ជិវ្ហិន្ទ្រិយ , កាយិន្ទ្រិយ , ឥត្ថិន្ទ្រិយ , បុរិសិន្ទ្រិយ , ជីវិតិន្ទ្រិយ , មនិន្ទ្រិយ , សុខិន្ទ្រិយ , ទុក្ខិន្ទ្រិយ , សោមនស្សិន្ទ្រិយ , ទោមនស្សិន្ទ្រិយ , ឧបេក្ខិន្ទ្រិយ , សទ្ធិន្ទ្រិយ , វីរិយិន្ទ្រិយ , សតិន្ទ្រិយនិងសមាធិន្ទ្រិយជានហេតុ។

## ការចែកឥន្ទ្រិយ ២២
## ដោយសហេតុក និង អហេតុក

**ឥន្ទ្រិយ៧** គឺ ទោមនស្សិន្ទ្រិយ , សទ្ធិន្ទ្រិយ, សតិន្ទ្រិយ បញ្ញិន្ទ្រិយ , អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ , អញ្ញិន្ទ្រិយ និង អញ្ញាតាវិន្ទ្រិយ ជាសហេតុក ។

**ឥន្ទ្រិយ៩** គឺ ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ , ឃានិន្ទ្រិយ , ជីវ្ហិន្ទ្រិយ, កាយិន្ទ្រិយ , ឥត្ថិន្ទ្រិយ, បុរិសិន្ទ្រិយ, សុខិន្ទ្រិយ , ទុក្ខិន្ទ្រិយ ជាអហេតុក ។

**ឥន្ទ្រិយ៦** គឺ ជីវិតិន្ទ្រិយ, មនិន្ទ្រិយ, សោមនស្សិន្ទ្រិយ, ឧបេក្ខិន្ទ្រិយ , វីរិយិន្ទ្រិយ និងសមាធិន្ទ្រិយ ជាសហេតុកផង អហេតុកផង ។

## ការចែកឥន្ទ្រិយ ២២
## ដោយខន្ធ

**ឥន្ទ្រិយ៧** គឺ ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ , ឃានិន្ទ្រិយ , ជីវ្ហិន្ទ្រិយ , កាយិន្ទ្រិយ , ឥត្ថិន្ទ្រិយនិងបុរិសិន្ទ្រិយជារូបក្ខន្ធ ។

**ឥន្ទ្រិយ៥** គឺ សុខិន្ទ្រិយ, ទុក្ខិន្ទ្រិយ, សោមនស្សិន្ទ្រិយ, ទោមនស្សិន្ទ្រិយ និងឧបេក្ខិន្ទ្រិយជាវេទនាខន្ធ ។

**ឥន្ទ្រិយ៨** គឺ សទ្ធិន្ទ្រិយ, វីរិយិន្ទ្រិយ , សតិន្ទ្រិយ , សមាធិន្ទ្រិយ , បញ្ញិន្ទ្រិយ , អនញ្ញតញ្ញស្សាមីតិន្ទ្រិយ , អញ្ញិន្ទ្រិយ , អញ្ញាតាវិន្ទ្រិយ ជាសង្ខារក្ខន្ធ ។

**ឥន្ទ្រិយ ១** គឺ មនិន្ទ្រិយ ជាវិញ្ញាណក្ខន្ធ ។

**ឥន្ទ្រិយ ១** គឺ ជីវិតិន្ទ្រិយ ជារូបក្ខន្ធផង ជាសង្ខារក្ខន្ធផង។

## ការចែកឥន្ទ្រិយ ២២

## ដោយអាយតនៈ

**ឥន្ទ្រិយ៥** គឺ ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ , ឃានិន្ទ្រិយ , ជីវ្ហិន្ទ្រិយ , កាយិន្ទ្រិយ ជាអាយតនៈ ៥ ។

**ឥន្ទ្រិយ ១** គឺ មនិន្ទ្រិយ ជាមនាយតនៈ ។

**ឥន្ទ្រិយ១៦** គឺ ឥត្ថិន្ទ្រិយ , បុរិសិន្ទ្រិយ , ជីវិតិន្ទ្រិយ , វេទនិន្ទ្រិយ៥ , និងសង្ខារក្ខិន្ទ្រិយ ៨ ជាធម្មាយតនៈ ។

## ការចែកឥន្ទ្រិយ ២២

## ដោយធាតុ

**ឥន្ទ្រិយ៥** គឺ ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ , ឃានិន្ទ្រិយ , ជីវ្ហិន្ទ្រិយ , កាយិន្ទ្រិយ ជាធាតុ ៥ ។

**ឥន្ទ្រិយ ១** គឺ មនិន្ទ្រិយ ជាវិញ្ញាណធាតុ ៧ ។

**ឥន្ទ្រិយ១៦** គឺ ឥត្ថិន្ទ្រិយ , បុរិសិន្ទ្រិយ , ជីវិតិន្ទ្រិយ , វេទនិន្ទ្រិយ ៥ , និងសង្ខារក្ខិន្ទ្រិយ ៨ ជាធម្មធាតុ ។

## ការចែកឥន្ទ្រិយ ២២

## ដោយ ភព៣

**ឥន្ទ្រិយ៨** គឺ ឃានិន្ទ្រិយ , ជីវ្ហិន្ទ្រិយ , កាយិន្ទ្រិយ , សុខិន្ទ្រិយ , ទុក្ខិន្ទ្រិយ , ទោមនស្សិន្ទ្រិយ , ឥត្ថិន្ទ្រិយ , បុរិសិន្ទ្រិយ មាននៅក្នុងកាមភព ។

**ឥន្ទ្រិយ២** គឺ ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ មាននៅក្នុងកាមភពផង រូបភពផង ។

**ឥន្ទ្រិយ១២** គឺ ជីវិតិន្ទ្រិយ,មនិន្ទ្រិយ, សោមនស្សិន្ទ្រិយ

, ឧបេក្ខិន្ទ្រិយ និងសង្ខារក្ខិន្ទ្រិយ៨ មាននៅក្នុងកាមភពផង រូបភពផង អរូបភពផង ។

ដូច្នេះក្នុងកាមភពមានឥន្ទ្រិយទាំង ២២ ក្នុងរូបភពមាន ឥន្ទ្រិយ ១៤ ក្នុងអរូបភពមានឥន្ទ្រិយ ១២ ។

## ការបែកឥន្ទ្រិយ ២២
## ដោយភូមិ

**ឥន្ទ្រិយ១០** គឺ ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ , ឃានិន្ទ្រិយ , ជីវ្ហិន្ទ្រិយ , កាយិន្ទ្រិយ , ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ , សុខិន្ទ្រិយ , ទុក្ខិន្ទ្រិយ និងទោមនស្សិន្ទ្រិយ មាននៅក្នុង កាមធម៌ ឬហៅថា កាមឥន្ទ្រិយ ។

**ឥន្ទ្រិយ៨** គឺ ជីវិតិន្ទ្រិយ, មនិន្ទ្រិយ , ឧបេក្ខិន្ទ្រិយ , សទ្ធិន្ទ្រិយ , វីរិយិន្ទ្រិយ , សតិន្ទ្រិយ , សមាធិន្ទ្រិយ និង បញ្ញិន្ទ្រិយ មាននៅក្នុងកាមធម៌ផង រូបធម៌ផង អរូបធម៌ផង លោកុត្តរធម៌ផង ។

**ឥន្ទ្រិយ១** គឺ សោមនស្សិន្ទ្រិយ មាននៅក្នុងកាមធម៌

ផង រូបធម៌ផង លោកុត្តរធម៌ផង ។

**ឥន្ទ្រិយ ៣** គឺ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ , អញ្ញិន្ទ្រិយ និងអញ្ញាតាវិន្ទ្រិយ មាននៅក្នុងលោកុត្តរធម៌ ។

## ការចែកឥន្ទ្រិយ ២២ ដោយកំណើត ៤ ខណៈបដិសន្ធិ

**ពួកទុគ្គតិសំសេទជៈ** មានយ៉ាងច្រើន ៩ គឺ ចក្ខុន្ទ្រិយ , សោតិន្ទ្រិយ, ឃានិន្ទ្រិយ, ជីវ្ហិន្ទ្រិយ, កាយិន្ទ្រិយ, ឥត្ថិន្ទ្រិយ ( ឬ បុរិសិន្ទ្រិយ ) ជីវិតិន្ទ្រិយ , មនិន្ទ្រិយ , និង ឧបេក្ខិន្ទ្រិយ ។

**ពួកសុគតិសំសេទជៈ** មានយ៉ាងច្រើន ១៤ គឺ ចក្ខុន្ទ្រិយ , សោតិន្ទ្រិយ, ឃានិន្ទ្រិយ, ជីវ្ហិន្ទ្រិយ, កាយិន្ទ្រិយ , ឥត្ថិន្ទ្រិយ ( ឬបុរិសិន្ទ្រិយ ) , ជីវិតិន្ទ្រិយ, មនិន្ទ្រិយ, សោមនស្សិន្ទ្រិយ ( ឬឧបេក្ខិន្ទ្រិយ ) សទ្ធិន្ទ្រិយ , វីរិយិន្ទ្រិយ , សតិន្ទ្រិយ , សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ ។

មានយ៉ាងតិច៩ គឺ ជីវ្ហិន្ទ្រិយ, កាយិន្ទ្រិយ , ជីវិតិន្ទ្រិយ

មនិន្ទ្រិយ , សោមនស្សិន្ទ្រិយ( ឬឧបេក្ខិន្ទ្រិយ ) សទ្ធិន្ទ្រិយ , វីរិយិន្ទ្រិយ , សតិន្ទ្រិយ និងសមាធិន្ទ្រិយ ។

**ពួកកាមទុគ្គតិឱបបាតិកៈ**

មានយ៉ាងច្រើន ៩ គឺ ដូចគ្នានឹងទុគ្គតិសំសេទជៈ ។

មានយ៉ាងតិច ៦ គឺ ឃានិន្ទ្រិយ , ជិវ្ហិន្ទ្រិយ , កាយិន្ទ្រិយ , ជីវិតិន្ទ្រិយ , មនិន្ទ្រិយ , និងឧបេក្ខិន្ទ្រិយ ។

**ពួកកាមសុគតិឱបបាតិកៈ**

មានយ៉ាងច្រើន១៤ គឺ ដូចគ្នានឹងកាមសុគតិសំសេទជៈ។

មានយ៉ាងតិច ១៣ គឺ វៀរបញ្ញិន្ទ្រិយ ។

មនុស្សដើមកប្ប មិនមានភាវិន្ទ្រិយ ។

**ពួកទុគ្គតិគព្ភសេយ្យកៈ**

មានយ៉ាងច្រើន ៥ គឺ កាយិន្ទ្រិយ , ឥត្ថិន្ទ្រិយ ( ឬ បុរិសិន្ទ្រិយ ), ជីវិតិន្ទ្រិយ, មនិន្ទ្រិយ និងឧបេក្ខិន្ទ្រិយ ។

មានយ៉ាងតិច ៤ វៀរភាវិន្ទ្រិយ ។

**ពួកសុគតិគព្ភសេយ្យកៈ**

មានយ៉ាងច្រើន ១០ គឺ កាយិន្ទ្រិយ , ឥត្ថិន្ទ្រិយ ( ឬ

បុរិសិន្ទ្រិយ) , ជីវិតិន្ទ្រិយ , មនិន្ទ្រិយ , សោមនស្សិន្ទ្រិយ ( ឬឧបេក្ខិន្ទ្រិយ ) , សទ្ធិន្ទ្រិយ , វីរិយិន្ទ្រិយ , សតិន្ទ្រិយ , សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ ។

មានយ៉ាងតិច ៨ វៀរបញ្ញិន្ទ្រិយ និងភាវិន្ទ្រិយ ។

**ពួកឱបបាតិករូបព្រហ្ម**

មានឥន្ទ្រិយ១០ គឺ ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ, ជីវិតិន្ទ្រិយ មនិន្ទ្រិយ , សោមនស្សិន្ទ្រិយ( ឬឧបេក្ខិន្ទ្រិយ ) សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ , សតិន្ទ្រិយ , សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ ។

**ពួកឱបបាតិកអសញ្ញសត្តព្រហ្ម**

មានឥន្ទ្រិយ ១ គឺ ជីវិតិន្ទ្រិយ ។

**ពួកឱបបាតិកអរូបព្រហ្ម**

មានឥន្ទ្រិយ៨ គឺ ជីវិតិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ , សទ្ធិន្ទ្រិយ , វីរិយិន្ទ្រិយ , សតិន្ទ្រិយ , សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ ។

## ៥ - ពលៈ

ពលៈ គឺ កម្លាំង សំដៅយកសេចក្តីមិនញាប់ញ័រ មានវចនត្ថថា :

**អកម្បនដ្ឋេន ពលំ**

ប្រែថា ធម៌ដែលឈ្មោះថា **ពលៈ** ព្រោះអត្ថថា មិនញាប់ញ័រ ។

**ពលីយន្តិ ឧប្បន្នេ បដិបក្ខធម្មេ**
**សហន្តិ មទ្ទន្តីតិ = ពលានិ**

ប្រែថា ធម៌ទាំងឡាយណា រមែងមានកម្លាំងសង្កត់សង្កិននូវបដិបក្ខធម៌ដែលកើតឡើងហើយ និងមានសេចក្តីអត់ធន់តស៊ូ កម្ចាត់បង់នូវបដិបក្ខធម៌ទាំងនោះ ដូច្នោះធម៌ទាំងនោះឈ្មោះថា **ពលៈ** ។

ធម្មតាអ្នកដែលជាមេទ័ព នាយពលទាំងឡាយ តែងមិនញាប់ញ័រក្នុងនាទីតំណែងមុខងាររបស់ខ្លួនយ៉ាងណា អង្គធម៌៩ប្រការ មានសទ្ធាជាដើម ក៏មិនញាប់ញ័រក្នុងនាទីមុខងាររបស់ខ្លួនក៏យ៉ាងនោះដែរ ហេតុនោះ ទើបឈ្មោះថា **ពលៈ** ។

សេចក្តីមិនញាប់ញ័ររបស់មេទ័ព នាយពលមានពីរប្រការ គឺ មិនញាប់ញ័រក្នុងនាទីគ្រប់គ្រងកូនពល អ្នកដែលនៅក្រោមបង្គាប់បញ្ជារបស់ខ្លួនផង និង ពេលណាប្រឈមមុខនឹងសត្រូវ ក៏មិនញាប់ញ័រ អាចវាយបំបែកពួកហ្វូងសត្រូវនោះបានផងនិងអាចកម្ចាត់បង់នូវអកុសលធម៌ដែលជាបដិបក្ខនឹងខ្លួននោះ ឲ្យវិនាសអស់ទៅបានផង ដូចសទ្ធាពលៈ មានសេចក្តីជ្រះថ្លាជឿយ៉ាងមុតមាំ មិនញាប់ញ័រ តែងតែអាចកម្ចាត់បង់នូវអកុសលដែលជាហេតុធ្វើឲ្យមិនមានសេចក្តីជ្រះថ្លា គឺ អសទ្ធិយឲ្យវិនាសអស់ទៅបាន យ៉ាងនេះជាដើមប្រការមួយ ។

មេទ័ពនាយពលខ្លះ មិនញាប់ញ័រក្នុងនាទីគ្រប់គ្រង កូនពលអ្នកដែលនៅក្រោមបង្គាប់បញ្ជារបស់ខ្លួនមែន ប៉ុន្តែពេលជួបនឹងហ្វូងសឹកសត្រូវហើយ មិនអាចវាយបំបែកហ្វូងសត្រូវនោះឲ្យចាលចាញ់បានទេ សេចក្តីនេះយ៉ាងណា ពលធម៌ដែលជាអកុសលធម៌ទាំងនោះ មានសេចក្តីមិនញាប់ញ័រក្នុងនាទីមុខងាររបស់ខ្លួន អាចគ្របសង្កត់អ្នកដែលនៅក្រោមការបង្គាប់បញ្ជារបស់ខ្លួន គឺ តាំងមាំនៅក្នុងអកុសលធម៌ដែលកើតព្រម

គ្នាជាមួយខ្លួនប៉ុណ្ណោះ លុះកាលណាកុសលធម៌ដែលជាបដិបក្ខនឹងខ្លួន កើតឡើងហើយ ក៏នឹងមិនអាចកម្ចាត់បង់បានត្រូវផ្តល់លទ្ធភាពទៅឲ្យផ្នែកកុសលវិញ ដូចអហិរិកពលៈ មានសេចក្តីមិនញាប់ញ័រ ក្នុងការមិនខ្មាសមិនខ្លើមចំពោះបាបទុច្ចរិត ប៉ុន្តែលុះកាលណាហិរិពលៈកើតឡើងហើយ អហិរិកពលៈ ក៏ត្រូវតែចាលចាញ់វិញមិនអាចក្រាញតាំងនៅបានទេ ធ្វើឲ្យចិត្តខ្មាសខ្លើម ចំពោះបាបទុច្ចរិត ដោយអំណាចរបស់ហិរិពលៈ យ៉ាងនេះជាដើម ប្រការមួយទៀត ដូចមានបាលីសំដែងថា :

**អសទ្ធិយេ កោសជ្ជេ ច មុដ្ឋស្សច្ចេ ច ឧទ្ធច្ចេ**
**អវិជ្ជាយ អហិរិកេ នោត្តប្បេ ច នកម្បរេ ។**
**តស្មា សទ្ធាទយោ សត្ត កុសលាទិ ពលានិ ច**
**យុត្តោសេវ អកម្បេន អបុញ្ញាបិ តំ នាមិកា ។**

ប្រែថា អង្គធម៌ ៧ ប្រការ មានសទ្ធាជាដើម ដែលជាកុសល និងអព្យាកត ទាំងអស់នេះឈ្មោះថា **ពលៈ** ព្រោះហេតុមិនញាប់ញ័រក្នុងអកុសលតាមលំដាប់ គឺ **សទ្ធា** រមែងមិនញាប់ញ័រក្នុងអកុសលធម៌ ដែលជាហេតុធ្វើឲ្យកើតការមិនជឿ,

***វីរិយ*** *រមែងមិនញាប់ញ័រក្នុងអកុសលធម៌ ដែលជាហេតុធ្វើឲ្យកើតសេចក្តីខ្ជិលច្រអូស,* ***សតិ*** *រមែងមិនញាប់ញ័រក្នុងអកុសលធម៌ដែលជាហេតុធ្វើឲ្យកើតសេចក្តីភ្លេចភ្លាំងស្មារតី ,* ***សមាធិ*** *រមែងមិនញាប់ញ័រក្នុងសេចក្តីរវើរវាយ ,* ***បញ្ញា*** *រមែងមិនញាប់ញ័រចំពោះការមិនដឹងធម៌តាមសេចក្តីពិត ,* ***ហិរិ*** *រមែងមិនញាប់ញ័រចំពោះការមិនខ្មាសមិនខ្ពើមបាបទុច្ចរិត ,* ***ឱត្តប្បៈ*** *រមែងមិនញាប់ញ័រចំពោះការមិនខ្លាចមិនស្ញុតបាបទុច្ចរិត ។*

*សូម្បីក្នុងផ្នែកអកុសលធម៌ក៏ដោយមាន* ***អហិរិក អនោត្តប្បៈ*** *ដែលប្រកបនឹងអកុសលចិត្តទាំងនោះ ក៏បានឈ្មោះថា ពលៈដែរ ព្រោះមិនមានសេចក្តីញាប់ញ័រក្នុងអកុសល សម្បយុត្តធម៌ដែលកើតរួមគ្នានឹងខ្លួនតែម្យ៉ាងប៉ុណ្ណោះ ។*

*សរុបសេចក្តីមក ធម៌ដែលជាកម្លាំងណា ធ្វើឲ្យសម្បយុត្តធម៌ដែលកើតរួមគ្នានឹងខ្លួន មានសេចក្តីស្វាហាប់រហូតអាចធ្វើសេចក្តីល្អឬសេចក្តីអាក្រក់ឲ្យសម្រេចបាន ធម៌នោះឈ្មោះថា* ***ពលៈ*** *។*

*ដូច្នោះ* ***ពលៈ*** *ទើបមានទាំងកុសលពលៈ និងអកុសលពលៈ ។*

អកុសលពលៈ មានកម្លាំងអត់ធ្មត់ មិនញាប់ញ័រ ចំពោះអកុសលធម៌ដែលជាពួកដូចគ្នានឹងខ្លួនតែម្យ៉ាងប៉ុណ្ណោះ ប៉ុន្តែមិនអាចមានកម្លាំងញាំញីកុសលធម៌ដែលជាបដិបក្ខនឹងខ្លួនបានទេ ។

កុសលពលៈ មានកម្លាំងអត់ធ្មត់មិនញាប់ញ័រចំពោះកុសលធម៌ផង និងថែមទាំងមានកម្លាំងញាំញីកម្ចាត់បង់នូវអកុសលធម៌ ដែលជាបដិបក្ខធម៌នឹងខ្លួនបានទៀតផង ។

## ពលៈ មាន ៩ ប្រភេទ

**១ - សទ្ធាពលៈ** ធម្មជាតិដែលមិនញាប់ញ័រក្នុងសេចក្តីមិនជឿចំពោះវត្ថុដែលគួរជឿ អង្គធម៌បានដល់ សទ្ធាចេតសិក ដែលប្រកបក្នុងសោភណចិត្ត ៩១ ។

**២ - វីរិយពលៈ** ធម្មជាតិដែលមិនញាប់ញ័រ ក្នុងសេចក្តីមិនព្យាយាម អង្គធម៌បានដល់ វីរិយចេតសិក ដែលប្រកបក្នុង វីរិយសម្បយុត្តចិត្ត ១០៥ ។

**៣ - សតិពលៈ** ធម្មជាតិដែលមិនញាប់ញ័រក្នុងការវង្វេងភ្លេចស្មារតី អង្គធម៌បានដល់ សតិចេតសិក ដែលប្រកប

ក្នុងសោភណចិត្ត ៩១ ។

**៤ - សមាធិពលៈ** ធម្មជាតិដែលមិនញាប់ញ័រក្នុងការមិនធ្វើចិត្តឲ្យតាំងមាំនៅក្នុងអារម្មណ៍តែមួយ អង្គធម៌បានដល់ឯកគ្គតាចេតសិក ដែលប្រកបក្នុងចិត្ត ៧២ ( វៀរអវីរិយចិត្ត ១៦ និងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ) ។

**៥ - បញ្ញាពលៈ** ធម្មជាតិដែលមិនញាប់ញ័រក្នុងការមិនដឹងធម៌តាមសេចក្ដីពិត អង្គធម៌បានដល់ បញ្ញាចេតសិកដែលប្រកបក្នុងញាណសម្បយុត្តចិត្ត ៤៧ ឬ ៧៩ ។

**៦ - ហិរិពលៈ** ធម្មជាតិដែលមិនញាប់ញ័រក្នុងសេចក្ដីមិនខ្មាសមិនខ្ពើមចំពោះបាបទុច្ចរិត អង្គធម៌បានដល់ ហិរិ-ចេតសិក ដែលប្រកបក្នុងសោភណចិត្ត ៩១ ។

**៧ - ឱត្តប្បពលៈ** ធម្មជាតិដែលមិនញាប់ញ័រក្នុងសេចក្ដីមិនខ្លាចមិនស្លុតចំពោះបាបទុច្ចរិត អង្គធម៌បានដល់ឱត្តប្បចេតសិក ដែលប្រកបក្នុងសោភណចិត្ត ៩១ ។

**៨ - អហិរិកពលៈ** ធម្មជាតិដែលមិនញាប់ញ័រក្នុងសម្បយុត្តធម៌ដែលជាបាបទុច្ចរិត អង្គធម៌បានដល់ អហិរិកចេតសិក

ដែលប្រកបក្នុងអកុសលចិត្ត ១២ ។

**៩ - អនោត្តប្បពលៈ** ធម្មជាតិដែលមិនញាប់ញ័រក្នុងសម្បយុត្តធម៌ជាបាបទុច្ចរិត អង្គធម៌បានដល់ អនោត្តប្បចេតសិក ដែលប្រកបក្នុងអកុសលចិត្ត ១២ ។

ពលៈ ៩ ប្រការនេះ មានអង្គធម៌ ៩ ស្មើគ្នានឹងប្រភេទរបស់ពលៈ ដែលមាន :-

អហិរិក និង អនោត្តប្ប ជាពលៈខាងផ្នែកអកុសលតែម្យ៉ាង ។

សទ្ធា សតិ បញ្ញា ហិរិ និង ឱត្តប្ប ជាពលៈផ្នែកខាងកុសលតែម្យ៉ាង ។

វីរិយ និងសមាធិជាពលៈបានទាំងផ្នែកខាងអកុសលផងទាំងផ្នែកខាងកុសលផងចូលគ្នា ដោយហេតុនោះ ទើបចាត់នូវពួកពលធម៌នេះ ទុកក្នុង មិស្សកសង្គហៈ ។

**សង្កេត :**

ឯកគ្គតាចេតសិក នៅក្នុងអវីរិយចិត្ត ១៦ និងវិចិកិច្ឆាសម្បយុត្តចិត្ត១ រមែងមិនរាប់ចូលក្នុងសមាធិពលៈទេ ដោយ

ហេតុផល ទំនងដូចនឹងសេចក្តីដែលបានសំដែងទុកក្នុងមគ្គង្គៈ រួចហើយ ។

## ៦ - អធិបតី

អធិបតី គឺ ជាសភាវធម៌ដែលទ្រទ្រង់នូវសភាពជាធំ លើសជាងធម៌ដទៃ ដែលកើតឡើងព្រមគ្នានឹងខ្លួន ដូចមាន វចនត្ថថា :-

**អធិមានំ បតិ = អធិបតិ**

ប្រែថា ធម៌ដែលជាម្ចាស់នៃធម៌ដែលរួមជាមួយគ្នានឹង ខ្លួន ឬធម៌ដែលជាធំលើសជាងធម៌ដែលជាប់ជាមួយនឹងខ្លួន ធម៌នោះឈ្មោះថា អធិបតី ។

ឬ **អធិកោ បតិ = អធិបតី**

ប្រែថា ធម៌ដែលជាម្ចាស់ជាធំ និង មានអំណាចលើស ធម៌នោះឈ្មោះថា អធិបតី ។

ឬ **យេអត្តាធីន វុត្តីនំ បត្តិយាធិបតី មតា**
